ឯកសារប្រវត្តិសាស្ត្រ

# ចៅហ្វាយគួយ

## វីរបុរសខ្មែរកម្ពុជាក្រោម

រៀបរៀងដោយ

**កែវ~សុវត្ថិ**

អនុសេនិយឯកនៃកងយោធពលខេមរជាតិ

ការផ្សាយរបស់សារពត៌មានអង្គរបុរី
ព.ស.២៥៤៩ - គ.ស.២០០៥

# វាចាអ្នកនិពន្ធ

សៀវភៅឯកសារប្រវត្តិសាស្ត្ររឿង «ចៅហ្វាយគុយ» នេះ កាលក្នុងសម័យសក្តិភូមិ ខ្ញុំបានបោះពុម្ពផ្សាយម្តងរួចទៅហើយ ។ កាលណោះ ខ្ញុំត្រូវគេទាក់កបញ្ចូលទ្រុងអស់ចំនួន១៧ថ្ងៃ, ដោយចោទថា ខ្ញុំថ្លើមពាសមេឃ ហ៊ានសរសេរប៉ះពាល់ដល់ព្រះចេស្តា ។

ឥឡូវនេះ, កាលៈទេសៈតម្រូវឲ្យខ្ញុំសំលៀងចុងប៉ាការយ៉ាងមុត ដើម្បីឆ្កិះកកាយប្រមាត់ជាំខ្មៅរបស់ស្តេចវង្វេងជាតិ បំផុសនូវស្មារតីតស៊ូរបស់វីរបុរសខ្មែរគ្រប់កាលសម័យ ដែលបានប្រយុទ្ធប្តូរស្លាប់ ជាមួយចោរយួនប្លន់ទឹកដី ដើម្បីការពារទ្រព្យសម្បត្តិរបស់ប្រទេសជាតិ ។

សៀវភៅឯកសារប្រវត្តិសាស្ត្ររឿង «ចៅហ្វាយគុយ» ឆ្លុះបញ្ចាំងពីសកម្មភាពយ៉ាងច្រាស់ជើង របស់យួនគ្រប់ស្រទាប់ ដែលកំពុងតែរៀបគំរោងការណ៍លេបទឹកដី និងជាន់ឈ្លីសិទ្ធិសេរីភាពរបស់បងប្អូនខ្មែរយើងនៅកម្ពុជាក្រោម ឲ្យទទួលទុក្ខវេទនាយ៉ាងខ្លោចផ្សា ដោយបាតដៃប្រឡាក់ឈាមរបស់ពួកវា ។

ភ្នំពេញ, ថ្ងៃទី២០ សីហា ១៩៧១

**កែវ~សុវត្ថិ**

# ឧទ្ទិសកថា

សូមឧទ្ទិសសៀវភៅឯកសារប្រវត្តិសាស្ត្រនេះជូនចំពោះ ៖

- ★ លោកសេនាប្រមុខ **លន់_នល់**
- ★ លោកឧត្តមសេនិយឯក **ស. សិរីមតះ**
- ★ លោកទីប្រឹក្សា **សឺន_ង៉ុកថាញ់**
- ★ លោកឧត្តមសេនិយទោ **ស្វូ_ការំខួយ**
- ★ លោកឧត្តមសេនិយត្រី **អ៊ិន_តាំ**
- ★ លោកវរសេនិយទោ **ម៉ាត់_ស្លែខាន់**
- ★ លោកវរសេនិយទោ **ភា_បូនី**
- ★ លោកវរសេនិយត្រី **ឡាច_សឿម**
- ★ យុទ្ធជនស្នេហាជាតិទាំងអស់
- ★ លោកចាងហ្វាងសារពត៌មានជាតិទាំងអស់
- ★ អ្នកនិពន្ធអក្សរសាស្ត្រជាតិទាំងអស់

# -១-

# ស្តេចខ្មែរ ស្តេចយួន

មុននឹងផ្ទាត់ទំព័រជំរាបមិត្តអ្នកអាន ពីប្រវត្តិដ៏គំរូរបស់ចៅហ្វាយគុយ ប្រមុខខេត្តព្រះត្រពាំង ដែលជាវីរបុរសខ្មែរដ៏អង់អាចនៅដែនដីកម្ពុជាក្រោមនោះ ខ្ញុំសូមបើកទំព័រប្រវត្តិសាស្ត្រ ចង្អុលពីក្រយៅថោកទាបនៃស្តេចវង្វេងជាតិខ្លះ ដែលឈ្លក់នឹងកាមតណ្ហាស្រីយួន បណ្តាលឲ្យបាត់បង់ទឹកដីដ៏ធំធេង ដូចមានប្រវត្តិសាស្ត្រចារទុកមកយ៉ាងជូរចត់ ឲ្យកូនខ្មែរជំនាន់ក្រោយជាអ្នកទទួលឈឺចាប់ខ្លោចផ្សា ។

ក្នុងឆ្នាំជូតអដ្ឋស័ក ពុទ្ធសករាជ២១៨០ គ.ស.១៦៣៦ (១) នៅប្រទេសខ្មែរយើងមានការរីករវរយ៉ាងខ្លាំង ដោយទ័ពយួនចូលឈ្លានពាន ក្នុងបំណងលេបយកទឹកដីកម្ពុជាក្រោម ។ ប៉ុន្តែកាលនោះ យុទ្ធជនជាតិយើងបានរួមកម្លាំងគ្នា វាយទប់វិញយ៉ាងអង់អាច រហូតទទួលជ័យជំនះដ៏ត្រចះត្រចង់ ។

កន្លងបានមួយរយៈក្រោយមក ស្តេចខ្មែរកើតវិកលចរិតក្នុងខ្លួន ភ្លេចសត្រូវស្ជពូជរបស់ជាតិ ដោយឈ្លក់វង្វេងនឹងសម្រស់កូនក្រមុំយួន បណ្តាលឲ្យទឹកភ្នែកប្រជារាស្ត្រខ្មែរ ហូរកកក្លាយជាឈាម បៀមតែសេចក្តីឈឺចាប់ដោយរកច្រកដោះស្រាយពុំរួច ។

ក្រោយពេលយុទ្ធជនខ្មែរដ៏អង់អាច វាយបណ្តេញក្បាលយួនចេញពីទឹកដីកម្ពុជាក្រោមហើយ ស្តេចខ្មែរក៏យាងទៅធ្វើទស្សនកិច្ចនៅក្រុងវ៉េ តាមសេចក្តីអញ្ជើញក្នុងឧបាយកលខ្មៅងងឹតរបស់ព្រះចៅយួន ។

ស្តេចខ្មែរយាងទៅដល់ក្រុងវ៉េ ក៏ប្រទះភ្នែកនឹងកូនក្រមុំស្តេចយ៉ាឡុង ឈ្មោះព្រះអង្គម្ចាស់ក្សត្រីយ៍ចូវ ដែលមានរូបឆោមស្រស់ប្រិមប្រិយ៍ខ្ចីល្អក់ដូចទេពអប្សរ ក៏ចាប់ចិត្តប្រតិព័ទ្ធភ្លាម ។ ចំណែកព្រះចៅយួន ក៏ប្រញាប់លើកថ្វាយជាបន្ទាន់ដែរ ដើម្បីសំរេចគោលបំណងយ៉ាងច្រាស់ជើងរបស់ខ្លួន ។

ព្រះអង្គម្ចាស់ក្សត្រីយ៍ចូវបានឡើងឋានៈជាមហេសី ព្រះជ័យជេដ្ឋាទី២ហើយ ក៏ប្រើល្បិចពង្វក់ខួរឲ្យឈ្លក់វង្វេងនឹងសម្រស់របស់វា ភ្លេចអគ្គមហេសីខ្មែរ ដែលម៉ែទុកឪពុកដាក់អស់រលីង ។

រីឯព្រះចៅក្រុងវ៉េវិញ សប្បាយចិត្តជាទីបំផុត ព្រោះព្រះចៅបានវែកញែកសាច់រឿងនេះយ៉ាងទូលំទូលាយ មុននឹងចំណាយសាច់មួយដុំថ្វាយព្រះចៅខ្មែរ ។ ម៉្យា

*(១) ច្បាប់ដើមសរសេរថា ៖ ឆ្នាំជូតអដ្ឋស័ក ពុទ្ធសករាជ ២១៧៨ គ.ស. ១៥៥៨ ។*

ងទៀតគេយល់ថា ៖ សង្គ្រាមរវាងខ្មែរនិងយួនចប់ត្រឹមនេះហើយ ព្រោះបានកូនស្រីពន្លកទៅអង្គុយទន្ទឹមនឹងព្រះរាជបល្ល័ង្កខ្មែរ ។ ព្រះបាទជ័យជេដ្ឋាទី២មិនបានចាប់ភ្លឹកថា ស្តេចយួនបង្កប់ពិសពុលយ៉ាងសាហាវដូច្នេះសោះ ក៏រវល់តែឈ្លក់នឹងសត្វជើងពីរ ភ្លេចមើលបណ្តារាស្ត្រខ្មែរ ដែលឃាមល្បាតនៅជុំវិញខ្លួនអស់រលីង ដោយយល់ថាឱពុកក្មេកនិងកូនប្រសារ មានរឿងអីនឹងកាប់សម្លាប់គ្នា បើឈាមសាច់វិញត្រូវបាញ់ជាផ្លូងមួយទៅហើយ ។ ត្រង់នេះហើយ ដែលខ្មែរយើងនិយាយប្រាប់គ្នាថា ព្រះបាទជ័យជេដ្ឋាទី២ យួនបានបញ្ចូលឈ្មោះក្នុងប្រវត្តិសាស្ត្រហៅថា «ព្រះអង្គម្ចាស់លឹង្គ» ។ ព្រោះគាត់និយមតែរឿងលឹង្គនេះហើយ ទើបកូនខ្មែរមួយភាគធំរស់នៅកម្ពុជាក្រោម ហូរទឹកភ្នែករាប់សតវត្សមិនអស់ រហូតមកដល់សព្វថ្ងៃនេះ ។

រឿងប្រពន្ធយួន ចាប់ដៃព្រះចៅខ្មែរមុនដំបូង ចង់ស្តីថាយ៉ាងម៉េចក៏សាសន៍គេមិនសូវអើពើដែរ ដល់នាងចូវមិនសូវជាអើពើ មានអីព្រះចៅខ្មែរស្រឡាញ់គេភ្លេចខ្លួនតែម្តង ឃើញព្រះជ័យជេដ្ឋាឈ្លក់វង្វេងខ្លាំងហើយ ទើបវាប្រើស្នៀតបន្តិចម្តងៗ ដោយមិនឲ្យដឹងខ្លួនយ៉ាងដាច់ខាត ។ នេះហើយពុតត្បុតស្រីយួន ដែលសម្ងំស្ងៀមប្រើទឹកមុខញញឹម ដើម្បីដកស្រង់ការពិសោធន៍ពីយើង មុនដំបូងវាស្ទាបស្ទង់យកចំណុចខ្សោយអស់ហើយ ទើបទីបំផុតវាវាត់យើងចាស់ដៃម្តង ។ រឿងនេះ ជីតាខ្ញុំកាលនៅបាក់ព្រា ខេត្តបាត់ដំបង គាត់មានប្រពន្ធយួនមួយ ។ គាត់ពិ-សោធន៍ជាមួយវាអស់ប្រហែល៥ឆ្នាំ ក៏ចែកផ្លូវគ្នាដើរទៅតែគ្មានកូនសោះ ។ គាត់បាននិយាយប្រាប់ខ្ញុំថា ៖ ពូជយួនចៅកុំភ្លេចឲ្យសោះ បើស្រឡាញ់វាគ្រាន់តែរាប់អានបានហើយ បើជ្រុលទៅសេពគប់ ត្រូវគុបវាឲ្យបានមុន កុំឲ្យវាគុបទាន់ តែបើវាគុបទាន់ហើយ សូម្បីខោស្លីបក៏អស់ដែរ ។ នេះជាបណ្តាំរបស់ជីតាខ្ញុំ ។

បន្តរឿងព្រះនាងអង្គចូវតទៅទៀត ព្រះនាងចូវប៉ិនត្បូញត្បែណាស់ម្តងថាអីចេះម្តងថាអីចុះ ធ្វើឲ្យព្រះជ័យជេដ្ឋាទី២វិលក្បុងគ្រប់ឧបាយកលរបស់វា ។

ព្រះនាងអង្គចូវជាបុត្រីទី៨ នៃព្រះចៅយ៉ាឡុងស្តេចក្រុងវេ ។ ប្រជារាស្ត្រយួនគេនិយមហៅឈ្មោះព្រះនាងថា «ព្រះអង្គម្ចាស់ក្សត្រីយ៍កូជិន» ។ ព្រះនាងតាំងពីមករួមរស់ជាមួយព្រះបាទជ័យជេដ្ឋាទី២ ក៏មានព្រះរាជបុត្រីមួយព្រះអង្គ ទ្រង់ថ្វាយព្រះនាមថា ព្រះអង្គម្ចាស់អង្គញ្ញក្សត្រី ។ កាលបើបានបុត្រីមួយហើយ ព្រះនាងអង្គចូវមានអាកប្បកិរិយាប្លែកពីព្រះចៅយើងជានិច្ច ។ ក្រោយមកទៀត ព្រះនាងសុំអំណាចពីព្រះអង្គដើរកំសាន្តគ្រប់ខេត្តខ័ណ្ឌ ។ ដល់ឲ្យដើរកំសាន្តយូរៗទៅតាំងបែកប្រាជ្ញា ក៏ឡើងថ្វាយបង្គំព្រះស្វាមី សុំអំណាចដើរសួរសុខទុក្ខបណ្តារាស្ត្រខ្មែរ ដែ-លរស់នៅភូមិស្រុកខេត្តឆ្ងាយៗ ជំនួសព្រះអង្គទៀត ។ ព្រះជ័យជេដ្ឋាទី២ក៏អនុញ្ញា

តដល់ព្រះនាងចូវ ឲ្យដើរសួរសុខទុក្ខរាស្ត្រស្រែចំការ គឺខេត្តបារាជ១ ហើយនិងខេត្តវាលប្រើស១ ។

ព្រះនាងអង្គចូវបានទទួលច្បាប់អនុញ្ញាតពីស្វាមីឲ្យដើរសួរសុខទុក្ខខ្មែរ តែចំនួន២ខេត្តទេ តែដោយអាងព្រះចៅខ្មែរជាស្វាមីសព្វព្រះទ័យខ្លាំង ក៏ជ្រុលហួសទៅបួនខេត្តឯណោះ។ គឺខេត្តញ៉ាត្រាង១ និងខេត្តទួលតាមោក១ទៀត (យួនសព្វថ្ងៃហៅឈ្មោះខេត្តនេះថា ធូយ៉ូវម៉ូក) ។

ល្បិចកលដ៏ក្រខ្វក់របស់ព្រះនាងចូវមិនត្រឹមតែប៉ុណ្ណឹងទេ វាហ៊ានដល់ទៅលួចផ្ញើសារពីប្រទេសខ្មែរ ទៅប្រាប់ដល់ទៅរដ្ឋាភិបាលយ៉ាឡុង អំពីគំរោងការណ៍សម្ងាត់របស់វា ដែលបានធ្វើរួចហើយ ដើម្បីឲ្យរដ្ឋាភិបាលវាចាត់ការបញ្ជូនមកជាបន្ទាន់ នូវបណ្តារាស្ត្រយួនណាដែលគ្មានដីធ្លីធ្វើស្រែចំការ ធ្វើផ្ទះសំបែង ព្រោះដីនៅស្រុកខ្មែរសល់ទំនេរច្រើនណាស់ មិនខ្វះឲ្យរាស្ត្រយួននៅទេ ។

ឧបាយកលនេះមានប្រសិទ្ធិភាពណាស់ មិនយូរប៉ុន្មានរាស្ត្រយួនក៏មករស់នៅច្រូឡូកច្រូឡំជាមួយខ្មែរ តកូនពូនជាចៅរាប់ក្បាលស្ទើរមិនអស់ ។ ដល់ឃើញរាស្ត្ររស់នៅកកកុញគ្រប់ទីកន្លែងហើយ គេក៏ប្រកាសប្រាប់បណ្តារាស្ត្រគេឲ្យដឹងគ្រប់គ្នាថា ៖ (ទឹកដីព្រះនាងកូជិនស៊ិន) យ៉ាងឥតអៀនខ្មាស់សោះតែម្តង ។ ចំណោទអស់ទាំងនេះត្រូវធ្លាក់ទៅលើព្រះជ័យជេដ្ឋាទី២ ដែលជាស្តេចគំរក់ចងក្រងប្រវត្តិសាស្ត្រយ៉ាងជូចត់ ទុកឲ្យជនជាតិខ្មែររងទុក្ខវេទនារហូតសព្វថ្ងៃ ក៏ព្រោះតែគំនិតព្រៃផ្សៃល្មោភតណ្ហារបស់ស្តេចអង្គនេះ ។

កូនខ្មែរជំនាន់ក្រោយត្រៀមខ្លួនជានិច្ច និងគាស់រំលើងឫសកែវយង់ឃ្នងរបស់ចោរបរទេស លើទឹកដីដ៏ធំធេងរបស់ខ្មែរ ដែលប្រវត្តិសាស្ត្របានចងក្រងទុកដោយអយុត្តិធម៌ ។

# -២-

# ចោរយួនប្លន់ខេត្តព្រះត្រពាំង

ដីកម្ពុជាក្រោមមានសណ្ឋានបួនជ្រុងញួយស្រប លាតសន្ធឹងពីទិសនិរតីទៅទិសព្វាយ័ព្យ ។ ព្រំប្រទល់ខាងលិចទល់នឹងកម្ពុជាកណ្តាល ខាងត្បូងនិងខាងកើតទល់នឹងសមុទ្រចិន ខាងជើងទល់នឹងនគរចំប៉ា ។ ទំហំដីមានប្រមាណមួយភាគបី ១/៣នៃកម្ពុជាកណ្តាល គឺប្រមាណ២៧០០គីឡូម៉ែត្រក្រឡាទ្វេគុណ ។ ដីនេះប្រវត្តិដើមជាកោះតូចៗ ដុះប្រមូលផ្តុំគ្នា ហើយក៏ក្លាយទៅជាដីទំនាបទាបស្មើ មានជីវជាតិ អាចដាំដំណាំបានផលល្អជាទីបំផុត ក្នុងជ្រោយឥណ្ឌូចិននេះ (Indochina) ។

ដីកម្ពុជាក្រោមពីអតីតកាលចែកជា១៧ខេត្ត ។ ខេត្តនីមួយៗសុទ្ធតែមានទំហំធំៗណាស់ ។ លុះមកដល់សម័យអាណានិគមបារាំង គេនាំគ្នាពង្រីកខេត្តទាំងនោះទៅជា២១ខេត្តវិញ ។ ខេត្តទាំង១៧សម័យអតីតកាលមានឈ្មោះដូចតទៅនេះ ៖

០១- ខេត្តព្រះត្រពាំង (ត្រាយិញ)
០២- ខេត្តពលលាវ (បាក់លីវ)
០៣- ខេត្តឃ្លាំង (សុកត្រាំង)
០៤- ខេត្តទឹកខ្មៅ (កាម៉ៅ)
០៥- ខេត្តពាម (ហាទៀង)
០៦- ខេត្តក្រមួន-ស (រ៉ាជយ៉ា)
០៧- ខេត្តបារាជ (ឡុងសៀង)
០៨- ខេត្តមាត់ជ្រូក (ចូវដុក)
០៩- ខេត្តរោងដំរី (តាយនិញ)
១០- ខេត្តព្រះសួគ៌ (ធូយ៉ូវម៉ូក)
១១- ខេត្តព្រៃនគរ (សៃហ្គន)
១២- ខេត្តមេ-ស (មី-ថ)
១៣- ខេត្តលង់ហោរ (យ៉ិញឡុង)
១៤- ខេត្តកំពង់ឫស្សី (ប៊ិនត្រែ)
១៥- ខេត្តព្រែកឫស្សី (កឹងថើ)
១៦- ខេត្តដំបូកកោង (ហ្គកុង)
១៧- ខេត្តផ្សារដែក (សាដែក)

ក្នុងខេត្តនីមួយៗ មានចៅហ្វាយខេត្តខ្មែរម្នាក់ជាអាណាព្យាបាលមើលការខុសត្រូវ ។ ខណៈនេះ ខ្ញុំពុំបានរៀបរាប់ពីសកម្មភាពដ៏ឃោរឃៅរបស់ចោរយួនមកលើបងប្អូនខ្មែរយើងនៅកម្ពុជាក្រោមទាំងអស់ទេ គឺគ្រាន់តែលើកយកខេត្តមួយ ក្នុងចំណោមខេត្តទាំង១៧នោះ មកបកស្រាយដើម្បីជាឯកសារដាស់ស្មារតីកូនខ្មែរជំនាន់ក្រោយទាំងអស់ ឲ្យចាប់អារម្មណ៍ពីប្រវត្តិជូរចត់របស់បុព្វបុរសជំនាន់មុន ដែលបានតស៊ូក្រាញនននាលក្នុងទីលានសមរភូមិ ដើម្បីការពារបូរណភាពទឹកដី ព្រះពុទ្ធសាសនា និងសិទ្ធិសេរីភាពប្រជាជនខ្មែររាប់សែននាក់ក្នុងទីរួមខេត្តព្រះត្រពាំង ដែលមានលោកឧកញ៉ាសេនាបតី សឺន-គុយ ជាប្រមុខខេត្តដ៏គំរូ ។

សម័យឧកញ៉ា សឺន-គុយ ជាសម័យប្រើកាំបិត ពូថៅ ដាវ លំពែងជាអាវុធ ហើយយកសេះដំរីជាយានជំនិះ នៅពេលស្រុកមានសង្គ្រាមឈ្លានពានម្តងៗ ។

ផែនការប្លន់យកទឹកដីកម្ពុជាក្រោមរបស់យើង មុនដំបូងស្តេចយួនបានចាត់មេទ័ពវាម្នាក់ឈ្មោះ ធីបេ មាឌធំដំបងហើយខ្ពស់កំព្រឹងវិស័យត្នោតលៃ មុខមាត់កាចសាហាវដូចខ្លាត្រូវរបួស បញ្ជាក់យ៉ាងច្បាស់ថាជាជនស្រែកឈាមអ្នកស្លូតត្រង់ ។

ធីបេទទួលបញ្ជាពីស្តេចយួន ឲ្យនាំទ័ពមួយកងវរសេនាតូច ចូលមកទប់ទល់ខ្មែរនៅជាយដែនកម្ពុជាកណ្តាល ហើយចាត់មេទ័ពម្នាក់ទៀតឈ្មោះ អុង-ឡូវ (ទ័ពនេះតាមឯកសារថា សាហាវជាងទ័ពណាទាំងអស់ ក្នុងចំណោមកងទ័ពយួនទាំងមូល) ប្រើឲ្យនាំទ័ព២កងវរសេនាតូច ចូលវាយសំរុកមកខេត្តព្រះត្រពាំងទាំងមូលឲ្យបាន ។

ដំបូងខ្ញុំនិយាយពីមេទ័ពយួនឈ្មោះ អុងធីបេ សិន ។ ទ័ពយួនធីបេ ក្នុងពេលបញ្ជាទ័ពចូលវាយទ័ពខ្មែរនៅតាមជាយដែនយើង វាវាយទប់ទល់ៗជាបណ្តោះអាសន្នតែប៉ុណ្ណោះ មិនអាចបញ្ជាទ័ពឲ្យចូលប្រយុទ្ធជាមួយទ័ពខ្មែរខ្លាំងក្លាបានទេ ព្រោះទ័ពខ្មែរនៅតាមជាយដែន ស្ថិតក្រោមបញ្ជាការលោក ម៉ិល ដែលមានល្បិចយុទ្ធសាស្ត្រក្នុងការប្រយុទ្ធយ៉ាងអង់អាចយូរឆ្នាំមកហើយ ។

ចំណែកអាមេចោរ អុង-ឡូវ បាននាំទ័ពពីរកងវរសេនាតូច ចូលទៅប្រយុទ្ធឡោមព័ទ្ធខេត្តព្រះត្រពាំង ដែលរដ្ឋាភិបាលយើងបានចាត់លោកឧកញ៉ាសេនាបតី សឺន-គុយ ឲ្យធ្វើជាចៅហ្វាយខេត្ត ។

លោកឧកញ៉ា សឺន-គុយ មាឌធំដំបងខ្ពស់ សម្បុរសណ្តែកបាយ មានទឹកមុខសស្អាត ផ្ទៃថ្ងាសធំទូលាយ សក់ស្រឡូតរាបស្មើទៅក្រោយ ។ លោកជាវីរជនម្នាក់មានចិត្តក្លាហានគ្រប់កិច្ចការទូទៅ ហើយបានចូលបំរើជាតិតាំងពីអាយុ២០ឆ្នាំ ដែលជាទីពេញចិត្តរបស់ប្រជារាស្ត្រខ្មែរ ។ រដ្ឋាភិបាលបានតែងតាំងងារជូនលោក ឧក-

ញ៉ាសេនាបតី សឹន-គុយ ជាអភិបាលខេត្តព្រះត្រពាំង ។ វីរជនរូបនេះ បរិបូណ៌ដោយគុណសម្បត្តិ ចរិយាសម្បត្តិ និងសុភាពរាបសា ស្គាល់តូចស្គាល់ធំ ហើយជាទីគោរពរាប់អានរបស់បណ្ដារាស្ត្រខ្មែរគ្រប់ជាន់ថ្នាក់ ។

តាំងពីលោកឡើងកាន់តំណែងអភិបាលខេត្តពេលណាមក លោកមិនសូវបានសំរាកទេ ព្រោះរឿងប្រយុទ្ធជាមួយយួន បានចោទឡើងស្ទើររាល់ថ្ងៃ ។ លោកប្រើសង្គ្រាមគ្រប់បែបសង្គ្រាមចិត្តសាស្ត្រ អប់រំប្រជារាស្ត្រឲ្យដើរទៅរកផ្លូវសុភមង្គល ឲ្យស្រឡាញ់ជាតិសាសនា ឲ្យចងបាច់សាមគ្គីវេញឧត្តមគតិជាធ្លុងមួយ រឹតចំណងមេត្រីភាពរវាងខ្មែរនិងខ្មែរឲ្យជិតស្និទ្ធ ។ សង្គ្រាមអាវុធ លោកចេញច្បាំងជាមួយទ័ពដោយផ្ទាល់ខ្លួន មិនថាយប់មិនថាថ្ងៃ ។

ឧកញ៉ា សឹន-គុយ ប្រមុខខេត្តព្រះត្រពាំង លោកមានសហការីជំនិតរបស់លោកទាំងអស់៥រូបសុទ្ធតែសហការីល្បីល្បាញកក្កងចំបាំង។ សហការីទី១ឈ្មោះភូឈ្មួយ គង់, លោកម៉ឺន ឯក, លោកតា ម៉ង់, លោកទេសា សោម (ខ្លះហៅអន្សា សោម) ហើយនិងលោកតា មនោ រស់ ។

សមាជិកទាំង៥រូបនេះ ជាដៃស្ដាំរបស់លោកឧកញ៉ា ធ្លាប់ហែលក្នុងភ្លក់សង្គ្រាមរាប់ឆ្នាំមកហើយៗមានជ័យជំនះលើពួកយួនជាដរាប ។

ភូឈ្មួយ គង់ កើតនៅភូមិស្វាយសៀម ស្រុកថ្កូវ ខេត្តព្រះត្រពាំង ជាសហការីទី១ ហើយជាមនុស្សអង់អាចក្លាហាន បរិបូណ៌ដោយសិលប្បសាទ កាប់មិនមុតដុតមិនឆេះ មានប្រាជ្ញាសំដីសំដៅលើសគេ ប៉ុន្តែជាមនុស្សចូលចិត្តរឿងសប្បាយស្រីញើបន្តិច ។

លោកតា ម៉ង់ កើតនៅស្រុក ឧម៉ុល ខេត្តព្រែកឫស្សី មាឌធំទ្រនាប់ ច្រមុះស្រួច សម្បុរខ្មៅស្រអែម ជាមេបញ្ជាការម្នាក់ កាប់មិនមុត ចេះបំបាំខ្លួនយ៉ាងពិតប្រាកដ ។

លោកហ្មឺន ឯក (តាមឯកសារថា មានស្រុកទេសមិនប្រាកដ) ជាមេបញ្ជាការក្លាហានលើសពីគេឯង ប្រាជ្ញាវាងវៃ ពូកពាក្យស្រគត់ស្រគំ មិនចេះមើលងាយមិត្តភក្តិឬនរណាទេ ហើយមិនសូវនិយាយលេងផ្ដេសផ្ដាសផង ។ គាត់មានមន្តអាគមគាថាលើសគេទាំងអស់ ចេះជប់ពលគ្មួចគំនួចស្មៅ ឱក្លាយជាកងទ័ពក៏មាន ចេះបំបាំងខ្លួនចូលប្រយុទ្ធមួយស្របក់បាន ។ ចំណែកតាអន្សា សោម និងតាមនោរស់ ចេះមន្តអាគមដូចគេឯងដែរ ប៉ុន្តែឯកសារមិនបានបញ្ជាក់ថា នៅស្រុកណាជាស្រុកណាទេ ។ គាត់ជាមនុស្សស្មោះត្រង់បំផុត ចំពោះលោកឧកញ៉ា គុយ ហើយស្អប់ខ្មើមយួនណាស់ ចូលច្បាំងជាមួយយួនម្ដងៗ ស្ទើរតែកូនក្នុងអង្រឹងមិនទុកផង ។ ស្នាដៃរបស់គាត់គេកោតខ្លាចគ្រប់ទិសទី ។

ទ័ពយួន អុង ឡូវ កំពុងចេញដំណើរជាបន្តបន្ទាប់គ្នា ពីខេត្តព្រៃនគរ បត់ក្បាលសំដៅទៅខេត្តព្រះត្រពាំង ដើម្បីបំផ្លាញជំរំទ័ពដ៏ល្បីល្បាញរបស់យើង ។ លោកចៅហ្វាយ គុយ មិនបានដឹងថា យួនគ្រោងការណ៍ជាន់ឈ្លីខេត្តរបស់លោកឲ្យវិនាសទេ ។ លោកស្មានខុសថា វាប្រាថ្នាវាយតែទិសខាងលិចប៉ុណ្ណោះ ។ ក្រោយមកស្រាប់តែ អ្នកយកការណ៍សម្ងាត់របស់យើង នាំពត៌មានមកប្រាប់លោកឧកញ៉ាថា មេទ័ពយួន អុងឡូវ វាកំពុងតែលើកទ័ពមកឡោមព័ទ្ធខេត្តព្រះត្រពាំងក្នុងថ្ងៃនេះហើយ ។

បន្ទាន់នោះ លោកឧកញ៉ាវាយការណ៍ប្រាប់មេបញ្ជាការរបស់លោកទាំងអស់ឲ្យត្រៀមខ្លួនចាំកំចាត់ពួកវាឲ្យចេញអស់ពីទឹកដី ។ លោកហ៊ឹន ឯក និងតា ម៉ង់ បានរៀបចំក្បួនការពាររង់ចាំជាស្រេច ឲ្យតែទ័ពអុងឡូវមកដល់ភ្លាម នឹងបញ្ជាទ័ពវាយលុកពុំបង្អង់ដៃឡើយ ។ មេបញ្ជាការនីមួយៗ ខំអស់ពីសមត្ថភាព កាន់អាវុធគ្រប់ៗដៃ ។

ក្បួនទ័ពលោក អន្សាសោម ត្រៀមចំនៅទិសខាងត្បូង ។ ក្បួនទ័ពតា ម៉ង់ នៅចាំច្រកកណ្តាល ។ ទ័ពលោកហ៊ឹន ឯក និងតា មនោរស់ នៅចាំច្រកខាងជើង ។ គឺទុកតែចន្លោះច្រកមួយ ឲ្យទ័ពយួនវាចូលក្នុងអន្ទាក់ឡោមព័ទ្ធតែប៉ុណ្ណោះ ។

មិនយូរប៉ុន្មានទីសមរភូមិមានចលនារស់រវើក ប្រៀបបាននឹងពស់វែកបើកពពារ ឬមហាព្យុះសង្ឃរាកំពុងតែរំលើងគល់ឈើ ។ ការប្រយុទ្ធបានយកទួលកោងដីក្រហម ជ្រោយអន្សាធ្វើជាសមរភូមិ ដែលមានវាលស្រឡះអាចមើលឃើញគ្នាទៅវិញទៅមក ត្រង់មានដើមឈើមួយធំជាសញ្ញា ។

ការប្រយុទ្ធជាមួយកងទ័ពយួននិងកងទ័ពខ្មែរ ប្រឡូកកាប់ចាក់គ្នាតាមក្បួនយុទ្ធសាស្ត្រសម័យនោះ បានប្រព្រឹត្តទៅអស់រយៈ៧យប់៧ថ្ងៃ កងទ័ពស្លាប់គរជើងលើគ្នាដូចដំបូក ឈាមហូរដាបពោះដីរ ។

មួយថ្ងៃក្រោយទៀត ទ័ពយួនអុងឡូវទាន់ដៃជាងទ័ពខ្មែរ ក៏វាយដោះដៃដកថយតាមក្បួនយុទ្ធសាស្ត្រ ទៅសម្ងំពួននៅក្នុងតំបន់ព្រៃក្រាស ដើម្បីរង់ចាំគ្នាវាបញ្ជូនទ័ពជំនួយមកតាមក្រោយទៀត ។ យួនរត់ទៅបាត់ប្រហែល៣ថ្ងៃ ក៏ប្រមូលបានគ្នីគ្នាបានច្រើនជាងមុន ហើយលើកមកម្តងទៀត តម្រៀបក្បាលគ្នាដូចកណ្តាញ់ ។ ការប្រយុទ្ធបានចាប់ផ្តើមឡើងយ៉ាងសាហាវ ។ ម្តងនេះគ្នាវាមានកម្លាំងជាងមុនមួយជាពីរ ។ មើលទៅក្នុងសមរភូមិ ពលទាហានខ្មែរសម្លាប់ទ័ពយួនដូចសត្វពន្លាត់ ។ ប៉ុន្តែដោយពុំមានទ័ពជំនួយ យើងទន់ដៃជាងយួនច្រើន ។ មេទ័ពម្នាក់ៗ កាលបើយល់ស្ថានការណ៍សឹក ពេលនេះបែបដុនដាប ក៏បញ្ជាទ័ពឲ្យវាយដោះដៃមួយរយៈសិន ។

ងាកមើលទៅទ័ពលោកហ្មឺន ឯក ដែលកំពុងប្រយុទ្ធជាមួយពួកយួនមួយចំនួនធំ ពុំអាចទប់កម្លាំងជាមួយវាបាន ក៏បញ្ជាទ័ពថយតាមរបៀបយុទ្ធសាស្ត្រដែរ ។ ដកទ័ពថយផុតហើយ លោកហ្មឺនឯកក៏ស្ទុះទៅវាលស្មៅម្ខាង លើកដៃប្រណម្យឈ្លីបាតដៃ សូត្រមន្តអាគមបំបាំងខ្លួន ហើយរត់ទៅគួចគំនួចស្មៅច្រើនគំនួច ជុបធ្វើជាពលសេនាសិល្ប ដើម្បីប្រយុទ្ធតទល់ឃាំងដំណើរសត្រូវ ។

តាមឯកសារបានបញ្ជាក់ថា ទ័ពសិល្បរបស់ហ្មឺនឯក កាលបើជុបរួចហើយក៏ស្រែកបន្ទរសម្លេងក្រេវៗបីបទ រំពងព្រមគ្នាមួយរំពេច ។ ទ័ពយួនកាលបើឃើញទ័ពខ្មែរច្រើនដូច្នេះ ព្រឺខ្លួនឡើងសម្បុរគីង្គក់ ចង់រកកលដាក់មេផាយ ។ ប៉ុន្តែមេវាស្រែកគំរាមកំហែង ឲ្យចូលប្រឡូកជាមួយទ័ពសិល្បហ្មឺនឯកទាំងប្រថុយស្បែក ។ ប្រយុទ្ធបានមួយសន្ទុះ ពួកយួនភ័យស្លាំងមុខ បែកញើសជោកថ្ងាស ដោយកាប់ត្រូវតែទងស្មៅជាច់រប៉ាត់រប៉ាយ ហើយកំទេចស្មៅនោះ ហើរចូលភ្នែកពួកវា បណ្តាលឲ្យឈាមហូរត្របាញ់ រកមើលទិសតំបន់អ្វីពុំឃើញសោះឡើយ ។ លោកហ្មឺនឯក ឃើញសភាពការណ៍ដូច្នោះ ក៏ចូលទៅប្រឡូកជាមួយទាហានយួនតែម្នាក់ឯងទៀត ។ ពួកវាត្រូវស្លាប់គរជើងលើគ្នា ដោយឥទ្ធិពលរបស់ហ្មឺនឯក ។

បើយើងងាកទៅមើលលោកតា ម៉ង់ ម្តងវិញ កាលបើឃើញលោកហ្មឺនឯកសម្លេះយួនតែម្នាក់ឯងដូច្នេះ គាត់ក៏បញ្ជាទ័ពរបស់គាត់ ឲ្យទៅជួយយ៉ាងបន្ទាន់រហូតដល់ទាហានយួន ទប់កម្លាំងតទៅទៀតមិនបាន ក៏នាំគ្នារត់ប្រាសអាយុ បាតជើងសព្រាតតែម្តង ។

ទោះបីត្រូវទទួលបរាជ័យយ៉ាងអាម៉ាស់ដូច្នេះក៏ដោយ ក៏ទ័ពអាចោរយួនឈ្លានពាន ពុំព្រមដកថយទៅក្រុងវិញដែរ គឺនៅបង្កប់ខ្លួនក្នុងព្រៃស្រោង រួចចាត់គ្នាវាឲ្យនាំសារទៅប្រាប់ចៅហ្វាយធំ ដើម្បីសុំជំនួយកងទ័ពមកទៀត ។

ចំណែកទ័ពខ្មែរយើង ក្រោយពីបានទទួលជោគជ័យ ដោយស្នាដៃដ៏កំពូលរបស់ហ្មឺនឯកមក លោកចៅហ្វាយគុយសប្បាយចិត្តណាស់ ក៏រៀបចំពិធីជប់លៀងយ៉ាងគគ្រឹកគគ្រេង ដើម្បីលើកទឹកចិត្តយុទ្ធជនស្នេហាជាតិ ។

▷ ▷

▷

# -២-

# សកម្មភាពចៅហ្វាយគុយ

យើងផ្អាករឿងចំបាំងមួយគ្រាសិន ដើម្បីងាកទៅតាមដានសកម្មភាពរបស់មេបញ្ជាការទាំង៥ ដែលជាសហការីផ្ទាល់របស់លោកចៅហ្វាយគុយ ។

បណ្ដាសហការីទាំងអស់ លោក ទេសាសោម គាត់មានវិបត្តិផ្លូវចិត្តជាមួយលោក ហ៊ីនឯក យូរមកហើយ ។ ទោះបីជួបឃើញញញឹមចាប់ដៃគ្នា ក៏ស្ថិតនៅក្នុងលក្ខណៈជាអាថ៌កំបាំងទាំងអស់ដែរ ។

តាំងពីចូលបំរើក្នុងកងទ័ពរបស់លោកចៅហ្វាយគុយ លោកហ៊ីនឯកគ្មានប្រាថ្នាអ្វី ក្រៅពីទឹកចិត្តស្នេហាជាតិដោយស្មោះត្រង់ ដើម្បីចេញកំចាត់ចោរយួនឈ្លានពាននោះទេ ។ កិច្ចការរបស់គាត់ចំពោះជាតិ ធ្វើឲ្យលោកចៅហ្វាយ សឹន-គុយ ប្រមុខខេត្តព្រះត្រពាំងស្រឡាញ់ពេញចិត្តយ៉ាងខ្លាំង ។

លោក ទេសាសោម ក៏មានគុណសម្បត្តិប្រហាក់ប្រហែលគ្នា នឹងលោកហ៊ីនឯកដែរ ។ ម្នាក់ៗសុទ្ធតែជាមេទ័ព ដែលមានថ្វីដៃខ្លាំងពូកែរៀងៗខ្លួន ។ ប៉ុន្តែបើនិយាយពីស្វាហាប់ហើយអង់អាចវិញ ប្រាកដជាលោក ហ៊ីនឯក គ្មានគូផ្ទឹមឡើយ ។

នៅពេលដែលពួកយួនបាក់ទ័ព រត់ខ្ចាត់ខ្ចាយអស់ទៅនោះ មេបញ្ជាការខ្មែរយើងម្នាក់ៗ ខំដើរប្រមូលកងទ័ពដែលសល់ពីស្លាប់ មកផ្តុំគ្នាបោះជំរំសំរាកកាយ។ ប្លែកតែលោកតា ម៉ង់ និងលោក ហ៊ីនឯក ពីរនាក់ប៉ុណ្ណោះទេ ដែលពុំបានឈប់សំរាកដោយស្ងៀមស្ងាត់ ព្រោះគាត់កំពុងតែរិះរកគ្រប់មធ្យោបាយ ដើម្បីទប់ទល់នឹងបច្ចាមិត្រ ក្រែងវារត់ទៅបង្កទ័ពវាយសំរុក ចូលមកក្នុងខេត្តព្រះត្រពាំងជាថ្មីម្តងទៀត ។

មេទ័ពទាំងពីរ បានបណ្តើរគ្នាត្រសងទៅរកដើមឈើមួយធំខ្ពស់បែកមែកសាខា មានម្លប់ត្រឈឹងត្រឈៃ នៅឆ្ងាយដាច់ស្រយាលពីគេឯង ។

អង្គុយស្រួលបួលហើយ ហ៊ីនឯក ក៏ផ្តើមបន្លឺពាក្យថា ៖

- ពេលនេះ, ពិតមែនតែយួនវាបាក់ទ័ពរត់ខ្ចាត់ខ្ចាយអស់, ប៉ុន្តែវាមិនទាន់ចុះចាញ់យើងទេ ។ យើងធ្លាប់ឮល្បីយូរហើយ ទ័ពអុងឡូវនេះកាចសាហាវណាស់ ។ កាលពីលើកមុន យើងទប់ទល់ជាមួយវាស្ទើរមិនឈ្នះម្តងរួចទៅហើយ ។ បើយើងមិនរកមធ្យោបាយតាមដានវា សម្លាប់បំបាត់ពូជពីផែនដីយើងទេ ថ្ងៃក្រោយប្រាកដជាវាបង្កទ័ព មកឈ្លានពានយើងទៀតពុំខានឡើយ ។

សព្វថ្ងៃនេះ វាប្រើគ្រប់មធ្យោបាយ តាំងពីសង្គ្រាមផ្លែងាវ រហូតដល់សង្គ្រាមចិត្តសាស្ត្រ ។ វាដើរពន្យល់បញ្ចុះបញ្ចូល បោកបញ្ឆោតស្មារតីទន់ខ្សោយរបស់បងប្អូនខ្មែរយើង ឲ្យស្រឡាញ់របបគ្រប់គ្រងរបស់វា ។ វាហ៊ានចាយលុយដោយឥតសំចៃដៃ ដើម្បីទិញក្បាលជនវង្វេងជាតិមួយចំនួនតូច ឲ្យបំរើផលប្រយោជន៍ខ្មៅងងឹតរបស់វា ។ ចំពោះខ្ញុំដែលមានឈាមជ័រជាខ្មែរ ពូជអ្នកចំបាំង គឺមិនព្រមលក់ឧត្តមគតិយ៉ាងដាច់ខាត ហើយប្ដេជ្ញាចិត្តតស៊ូរហូតថ្ងៃអវសាននៃជីវិត ។

លោកតា ម៉ង់ ព្ ហ្នឹនឯក និយាយយ៉ាងម៉ឺងម៉ាត់ដូច្នេះ គាត់សប្បាយចិត្តណាស់ ប្រញាប់ពោលពាក្យតបវិញឥតបង្អង់ ៖

- លោកនិយាយនេះចំជាត្រូវណាស់ ! យើងជាខ្មែរម្ចាស់ស្រុក ត្រូវតែមានស្មារតីអង់អាចតស៊ូជានិច្ច ។ ហើយជាពិសេស ត្រូវតែបង្កាត់កងទ័ពឲ្យចេះប្រើសង្គ្រាមចិត្តសាស្ត្រ ខ្ពស់ជាងវាមួយកំរិតទៀត ដើម្បីឲ្យស្របនឹងគំរោងការលោកចៅហ្វាយគុយ ដែលបានប្រកាសយ៉ាងមហោឡារិក ប្រាប់ប្រជាជនខ្មែរគ្រប់តំបន់ជនបទ កុំឲ្យជឿការឃោសនារបស់ពួកវា ហើយនាំគ្នាក្រោកឈរឡើង វាយកំទេចអំពើឈ្លានពានឲ្យវិនាសផុតពូជពីទឹកដីខ្មែរយើង ។

មួយជីវិតនេះ ខ្ញុំបានសច្ចាហើយជាស្រេច គឺដរាបណាជីវិតរបស់ខ្ញុំនៅរស់ ខ្ញុំមិនឲ្យចោរយួនប្លន់យកទឹកដីបានមួយចំអាមយ៉ាងដាច់ខាត ។ ប៉ុន្តែការដែលឲ្យខ្ញុំព្រួយបារម្ភទៅអនាគតនោះ គឺនៅលើមន្ត្រីយើង ដែលមិនព្រមចុះសំរុងគ្នា ដូចទឹកនិងប្រេង ។ អ្នកខ្លះស្រែកបន្ទរហែអើៗតែមាត់ តែចិត្តគំនិតខ្មៅក្រខ្វក់ ពុករលួយរកលេខដាក់គ្មាន ។ ខ្លះខំតស៊ូក្រាញននៀលក្នុងសមរភូមិ ត្រឡប់ជាត្រូវទទួលពាក្យចោទយ៉ាងអយុត្តិធម៌ទៅវិញ ។

ដូច្នេះ តើកម្លាំងសាមគ្គីស្ថិតនៅត្រង់ណា ?

លោកតា ម៉ង់ ដកដង្ហើមធំមួយរយៈ ទើបបន្តទៀត ៖

សព្វថ្ងៃនេះ សង្គ្រាមឈ្លានពានបានរាតត្បាតស្ទើរតែគ្រប់ខេត្តរបស់យើងនៅផ្នែកខាងដែនដីក្រោមនេះទៅហើយ ។ ប៉ុន្តែខេត្តព្រះត្រពាំងយើង មានវាសនាអាក្រក់ ហើយធ្ងន់ជាងខេត្តគេទាំងអស់ ។ ឥឡូវនេះ បើយើងមិនចាត់ការតាមបំផ្លាញជំរករបស់ពួកវាភ្លាមៗទេ យើងប្រាកដជាទទួលគ្រោះថ្នាក់ទៅថ្ងៃក្រោយមិនខាន

ប៉ុន្តែរឿងហ្នឹង លោកមេទ័ពប្រហែលជាជ្រាបខ្លះហើយ ចំពោះអំពើដែលសហការីខ្លះរបស់លោកសេនាបតី រៀបគំរោងការឈ្លានិសតែគ្នាឯង ដើម្បីដណ្ដើមអំណាចនិងបុណ្យស័ក្តិ ។ តួយ៉ាងដូចភូឈ្មួយ គង់ ជាឧទាហរណ៍ ។ ជននេះដើរផ្ទិះផ្ទៀលគេពីសំណាក់មួយទៅសំណាក់មួយ បង្កើតជាចលាចលផ្ទៃក្នុងគួរឲ្យព្រឺខ្លាច ។

ប៉ុន្តែរឿងហ្នឹងយើងគួរតែបញ្ចប់វាតែប៉ុណ្ណឹងចុះ ព្រោះយើងជាអ្នកដេកព្រៃដែលពុំមានពេលនឹងជំរះបញ្ជីផ្ទៃក្នុងឲ្យជ្រះស្រឡះ ក្រៅពីលោកចៅហ្វាយឡើយ។

ហ៊្មឹនឯកពុតាម៉ង់ ពោលពាក្យយ៉ាងក្បោះក្បាយដូច្នេះ ក៏បើកភ្នែកមូលក្រឡង់ដូចប្រាក់កាក់ បញ្ជាក់សួរថែមទៀត ៖

– យី ! ពុំមែនទេឬលោក ? ព្រោះអ្នកខ្លះច្រើនតែបញ្ចេញលក្ខណៈតាមសំបកក្រៅ តែគំនិតមារយាទជ្រៅជ្រះ ហើយធ្វើការជនផលទៀតផង ។ បើតាមខ្ញុំដឹងអាកប្បកិរិយាភូឈ្មួយ គង់ តែប៉ុណ្ណឹងទេ ព្រោះការវាយអែបស៊ីអបវាជារឿងម៉្យាងសំរាប់មនុស្សដែលមានចារិករបៀបនេះ ។ យើងយកជាការពិតក្រែងមិនបានណា៎

តា ម៉ង់ ងក់ក្បាលមួយៗ រួចបញ្ជាក់តទៀត ៖

– លោកនិយាយនេះខ្ញុំស្តាប់បានហើយ ៗមិនមែនបានសេចក្តីថា ខ្ញុំស្អប់ខ្ពើមឬច្រណែននឹងមុខការរបស់គេនោះទេ ។ ប៉ុន្តែតាមការសង្កេតផ្ទាល់របស់ខ្ញុំ ខ្ញុំយល់ថាមនុស្សល្អឬអាក្រក់ ប្រាកដជាបញ្ចេញអាកប្បកិរិយាយ៉ាងជាក់ច្បាស់ឲ្យយើងដឹងជាពុំខាន ។

លោក ហ៊្មឹនឯក ឯងមានចាប់អារម្មណ៍ទេ កាលលោកសេនាបតីហៅទៅរួមប្រជុំលើកមុន លោកបានបញ្ជាក់ផ្តែផ្តាំជាចុងក្រោយថា ៖

– ការប្រយុទ្ធផ្ទាល់ជាមួយខ្មាំង កុំឲ្យមើលងាយខ្មាំង ថាអន់ថយជាងយើងឲ្យសោះ ។ ការតស៊ូហាត់ពត់ស្មារតីកុំឲ្យតក់ស្លុត ជាការរបស់កងទ័ព ។ សាមគ្គីវេញត្របាញ់ឲ្យបានជាធ្លុងមួយ ក៏ជាការរបស់កងទ័ពដែរ ។ ហើយលោកមានប្រសាសន៍ទៀតថា ៖

ការសន្តោសន្តាទៅវិញទៅមក រវាងនាយទាហាននិងនាយទាហាន ក៏ចាត់ទុកជាមហាគ្រឹះយ៉ាងមាំ សំរាប់ជាតិសាសន៍នីមួយៗ ។ ពិសេសទៅទៀត ស្រុកកើតសង្គ្រាម កុំច្រឡូកច្រឡំរឿងស្រីញីឲ្យសោះ ព្រោះស្រីវាជាអាវុធដ៏សាហាវ ឬជាដំបៅមហារីកក្នុងកងទ័ព ។ យើងត្រូវចាំទៀតថា យើងជាខ្មែរត្រូវយកប្រពន្ធខ្មែរ ។ បើយកប្រពន្ធយួន ក្នុងពេលស្រុកកើតសង្គ្រាមនេះ នយោបាយជាតិប្រាកដជាទន់ខ្សោយជាពុំខាន ។

ប្រសាសន៍របស់លោកសេនាបតី មិនទាន់បានប៉ុន្មានថ្ងៃផង ល្បង គង់ ប្រើស្នៀតនេះលើសដើមទៅទៀត។ លោកមើលឃើញទេម្លៃណោះ ស្រាប់តែបណ្តើរស្រីក្រមុំយួនយ៉ាងស្អាតលេខ១ យកមកកៀកកើយស្មើរតែភ្លេចការងារអស់រលីង ។ ខ្ញុំព្រួយណាស់ ក្រែងស្រីយួននោះ វាជាភ្នាក់ងាររបស់យួនក៏មិនដឹង ។

លោក ហ៊្មឹនឯក ងក់ក្បាលយល់ស្របនឹងសំដីដ៏ត្រឹមត្រូវរបស់លោកតា ម៉ង់ ហើយបន្លឺពាក្យតប់ទៅវិញ ៖

– លោកតាមានប្រសាសន៍នេះពិតជាត្រូវមែន ! ខ្ញុំពុំបានសង្កេតមើលលក្ខណៈវាឲ្យបានជិតដល់សោះ ។ តែខ្ញុំអាចចំណាំវាបានខ្លះៗយូរមកហើយ ខ្ញុំក៏លាក់ទុកក្នុងចិត្តមួយគ្រាសិនទៅ ។ បើវាហ៊ានលក់ខួរក្បាលឲ្យយួន ដោយបំរើនយោបាយរបស់វានោះ យើងត្រូវតែរួមកម្លាំងគ្នា កំចាត់វាបានមុនកាលៈទេសៈ ព្រោះបើទុកឲ្យវានៅនាំឲ្យតែចង្អៀតផែនដីទេ ។

ការចរចារវាងលោក ហ៊ីនឯក និងលោកតា ម៉ង់ បានផ្លាស់ប្តូរយោបល់គ្នា ពីសំណាក់មួយទៅសំណាក់មួយយ៉ាងឆាប់រហ័ស ។ ភ្លាមនោះស្រាប់តែឮសន្ធឹកខ្យល់ ស្រែកសន្ធាប់យ៉ាងរញ្ជួយដី ។ លោកហ៊ីនឯកនិងតាម៉ង់ ក្រឡេកមើលទៅចំហាងខ្លួន ឃើញទ័ពយួនក្បាលខ្លាប់រត់តម្រង់មកតែម្តង ។

មេទ័ពទាំងពីរមិនបង្អង់ឲ្យខាតពេលយូរទេ ប្រញាប់នាំគ្នាស្ទុះទៅកាន់ជំរំទ័ពរៀងៗខ្លួន ហើយស្រែកបញ្ជាទ័ពឲ្យចូលទៅប្រយុទ្ធជាមួយពួកវាភ្លាម ។

ការប្រយុទ្ធលើកនេះ ទ័ពខ្មែរយើងទន់ដៃយ៉ាងខ្លាំង ព្រោះពុំនឹកស្មានថាវាអាចបង្កទ័ពបានឆាប់រហ័ស ហើយមានគ្នាច្រើនក្បាលដូចស្រមោច បោលសំរុកចូលមកមិនខ្លាចស្លាប់អីចឹងសោះ ។

ទោះបីលោក ហ៊ីនឯក និងលោកតា ម៉ង់ លោកមនោរស់ លោកទេសាសោម ខំរួមគ្នាបញ្ចេញថ្វីដៃអស់ពីសមត្ថភាពយ៉ាងណាក៏ដោយក៏ពុំអាចទប់ទល់ជាមួយពួកវាបានដែរ ។ ឱកាសនោះ លោក ហ៊ីនឯក មានទឹកមុខក្រៀមសំដែងការអស់សង្ឃឹមជាខ្លាំង ។

គូប្រយុទ្ធបានប្រទ្បុកជាមួយគ្នាអស់ពេលមួយយប់មួយថ្ងៃ ។ កងទ័ពយើងមានគ្នាតិចកម្លាំងខ្សោយ ក៏វាយដកទ័ពថយទៅរកទិសដៅដែលលោកមេទ័ព ហ៊ីនឯក បានបញ្ជាទុកជាស្រេច ។

ចំណែកលោកមេទ័ពដ៏ក្លាហាននោះវិញ ហក់រឹងទៅឈរពាំងពីមុខទ័ពសត្រូវ ហើយសូត្រគាថាបំបាំខ្លួន ព្រមទាំងគួចស្នៅជប់ពលវាល់ម៉ឺនទាក់ប្រយុទ្ធតទល់នឹងទ័ពយួន អស់ពេលមួយរយៈធំ ទើបភៀសខ្លួនទៅតាមកងទ័ពខ្មែរ ដែលបានវាយដកថយផុតបាត់ស្រមោល ។

លោកចៅហ្វាយ គុយ ក្រោយពីបានដឹងថា ខ្មែរយើងបាក់ទ័ពចាញ់យួនហើយ លោករសាប់រសល់ក្នុងចិត្តយ៉ាងខ្លាំង ។ មួយសន្ទុះ ទាហានម្នាក់រត់ត្រហេបត្រហបមកជំរាបលោកថា ៖

លោក ហ៊ីនឯក និងតាម៉ង់ ព្រមទាំងលោក មនោរស់ បាក់ទ័ពចាញ់គេហើយ ។ លោក ហ៊ីនឯក បានបញ្ជាខ្ញុំបាទ ឲ្យមកអញ្ជើញព្រះតេជគុណរៀបចំខ្លួនចេញពីទីនេះភ្លាម ព្រោះទ័ពយើងនៅរង់ចាំទទួលព្រះតេជគុណខាងក្រៅឯណោះ ។ សូម

ព្រះតេជគុណាប្រញាប់បន្តិច ទ័ពអុងឡូវវាវាយលុកមកដល់ឥឡូវនេះហើយ ។ ទ័ពវាសាហាវណាស់ ពួកយើងបោះជំរំទ័ពសំរាកក្នុងវត្តផ្ទូរដូង រង់ចាំព្រះតេជគុណាឯណោះទានប្រោស !

អ្នកនាំសារជំរាបលោកឧកញ៉ា ស្ទើរតែមិនទាន់ទាន់ផុតកន្ទុយមាត់ផង ស្រាប់តែភូឈួយ គង់ ដើមកដល់ បញ្ចេញកាយវិការយ៉ាងខែងរែង ។ ក្រោយខ្នងមានស្ពាយដាវយ៉ាងសង្ហា បោះជំហានធូន់ពាប់ទៅរកលោកឧកញ៉ា គុយ បំរុងហារមាត់ជជែក តែក្រឡេកឃើញទាហានម្នាក់នៅក្បែរនោះ ក៏ឈរស្ងៀមទៅវិញ ។ លោកចៅហ្វាយ សឹន-គុយ មើលមុខភូឈួយ គង់ បន្តិចក៏មានប្រសាសន៍ថា ៖

- លោកភូឈួយ ! សូមលោករៀបចំខ្លួន ចេញពីទីនេះទៅជាមួយខ្ញុំ ទ័ពយើងចាញ់គេហើយ ពួកវាបំរុងឡោមព័ទ្ធខេត្តយើង ។ សូមលោករៀបចំខ្លួនប្រញាប់បន្តិច ព្រោះលោកហ្នឹនឯក តាម៉ង់ រង់ចាំយើងនៅវត្តផ្ទូរដូងឯណោះ ។ បើយើងមិនគេចខ្លួនសិនទេ ជីវិតយើងត្រូវស្លាប់មុនការតស៊ូពុំខាន ។

ភូឈួយ គង់ ឮលោកឧកញ៉ា គុយ ប្រាប់ ក៏ធ្វើបុកយ៉ាងក្រអឺតក្រទម រួចប្រើប្រយោគមួយឃ្លាទៅកាន់ចៅហ្វាយនាយថា ៖

- មិនគួរសោះតែម្តង ! លោក ហ្នឹនឯក តាម៉ង់ ជាមនុស្សធ្លាប់អង់អាចពុំមានអ្នកណាប្រៀបផ្ទឹមបាន ចុះម្តងណោះ ហេតុម្តេចក៏ខ្សោយអីម្ល៉េះ ? បាក់ទ័ពចាញ់យួនស្រស់ៗអីចឹង ដូចជាមិនសមសោះ ។ ខ្ញុំស្តាយណាស់ដោយគ្មានខ្ញុំទៅប្រយុទ្ធជាមួយផង ពេលនោះបើមានខ្ញុំ ស្លាប់រស់ក៏ល្អមើលដែរ ។ តាមយោបល់ខ្ញុំយល់ថា, យើងមិនត្រូវរត់ចេញពីទីនេះទេ ! ត្រូវតែនៅប្រឡូកជាមួយពួកវាឲ្យឃើញសខ្មៅម្តងសិន ។ ព្រោះការស្លាប់និងរស់ វាជាករណីយកិច្ចរបស់ទ័ពទេតើ ។ លោកឧកញ៉ាមិនយល់ស្រប ក៏បន្ថែមទៀត ៖

- ការយល់របស់លោកភូឈួយ ពេញជាត្រូវហើយ ! ប៉ុន្តែលោកកុំភ្លេចថា ខ្លាពីរខាំគ្នា ត្រូវតែមួយចាញ់មួយឈ្នះ យ៉ាងណាមិញយុទ្ធជនម្នាក់ៗ តើមានអ្នកណាមួយចង់ធ្វើខ្លួនឲ្យបរាជ័យ ?... គឺគ្មានទាល់តែសោះ ។ ឥឡូវនេះកុំនិយាយច្រើនត្រូវតែចេញពីទីនេះមួយគ្រាសិន ។

ដល់ពេលលោកចៅហ្វាយ គុយ បង្ខំខ្លាំងពេក ទើបភូឈួយគង់យល់ស្របព្រមគេចខ្លួនពីទីនេះទាំងក្តៅក្រហាយ ។ ប៉ុន្តែ ការក្បត់របស់ភូឈួយ គង់ លោកចៅហ្វាយ គុយ មិនបានជ្រាបទេ ព្រោះជនដែលបង្កប់ខ្លួន ត្រាំពិសស៊ីរូងផ្ទៃក្នុងពិបាកបើករបាំងមុខវាណាស់ ។

| | | |
|---|---|---|
| មិត្តអើយចាំចុះ | បងប្អូនស្រីប្រុស | មើលជាតិខេមរា |
| ក្នុងជំនាន់នោះ | សម័យឧកញ៉ា | ឈឺចិត្តខ្លោចផ្សា |

ស្នេហាទឹកដី លោកខំពុះពារ រក្សាខេមរា
ខេត្តខណ្ឌបុរី ក្លាយសមុទ្រទុក្ខ ។ ហ្នឹងឯកតាម៉ង់
មេទ័ពស្មោះត្រង់ ចិត្តខ្មែរបរិសុទ្ធ ដង្ហែរដើរតាម
ឧកញ៉ានាំមុខ ភូឈ្លួយកត់ទុក្ខ ក្បត់ជាតិដែនដី ។

ប្រមាណជាមួយខែកន្លងមក លោកចៅហ្វាយ គុយ បានកោះហៅសហការីទាំងអស់មករួមប្រជុំ ដើម្បីរិះរកមធ្យោបាយដេញកំចាត់ខ្មាំងចេញពីខេត្តព្រះត្រពាំង ។ កាលបើសហការីមកជួបជុំគ្នាហើយ លោកប្រមុខខេត្តក្រោកឡើងសំដែងការគួរសមក្នុងអង្គប្រជុំ រួចទើបមានប្រសាសន៍ថា ៖

– ម្តងនេះ យើងត្រូវទទួលបរាជ័យយ៉ាងជូរចត់ ។ ប៉ុន្តែយើងមិនតូចចិត្តទេ ! ធ្វើម្តេចគ្នាយើងមានចំនួនតិចជាងគេ ។ ឥឡូវនេះយើងប្រមូលគ្នីគ្នាបានខ្លះមកវិញហើយ ។ ខ្ញុំជឿជាក់ថា បើយើងរួមសាមគ្គីគ្នា ប្រាកដជាមានជំហររឹងប៉ឹង ក្នុងការវាយកំចាត់វាជាពុំខាន ។ យើងជាទាហាន ត្រូវតែយល់វិន័យកងទ័ពឲ្យច្បាស់ ស្តាប់បង្គាប់របស់មេដែលបញ្ជាឲ្យអនុវត្ត ។ មិនត្រូវរត់ចោលសមរភូមិ នៅពេលដែលកំពុងប្រយុទ្ធជាមួយខ្មាំងទេ ។ ត្រូវតាំងចិត្តមោះមុតប្តូរស្លាប់ប្តូររស់ដើម្បីជាតិសាសនា ។

ចំណែករូបខ្ញុំ ! សូមអស់លោកកត់ទុកក្នុងចិត្តចុះ មួយជីវិតនេះ ខ្ញុំសុខចិត្តស្លាប់ ដើម្បីជាតិមាតុភូមិជាទីស្នេហា គឺមិនរស់នៅក្រោមការជិះជាន់របស់បច្ចាមិត្រយ៉ាងដាច់ខាត ។

ម្យ៉ាងទៀត កងទ័ពយើងត្រូវតែចេះវិជ្ជាចិត្តសាស្ត្រ ប្រាប់ពន្យល់បងប្អូនកម្មករ កសិករ រាស្ត្រស្រែចំការឲ្យភ្ញាក់រលឹកស្មារតីឡើង កុំចាញ់ឧបាយកលយួនឲ្យសោះ ព្រោះវាជាសត្រូវស្លរពូជរបស់ខ្មែរប្រចាំសតវត្សមកហើយ ។

ដំបូន្មានរបស់លោកចៅហ្វាយ គុយ ធ្វើឲ្យសហការីទាំងអស់ពេញចិត្តយ៉ាងខ្លាំងណាស់ ហើយប្តេជ្ញាចិត្តអនុវត្តគោលការណ៍ទាំងនេះ រហូតបានសំរេចជោគជ័យ

រំពេចនោះលោកតា ម៉ង់ ក៏ក្រោកឈរឡើងហើយនិយាយថា ៖

– ប្រសាសន៍របស់លោកចៅហ្វាយម្ចាស់ ប្រាកដជាមានតម្លៃ ពុំអាចវាស់ស្ទង់បានឡើយ ។ ប៉ុន្តែ ខ្ញុំបាទព្រួយបារម្ភជាទីបំផុត ដោយខ្លាចក្រែងមានពួកយើងដែលធ្វើការផ្ទាល់នឹងលោកម្ចាស់ បែកបាក់សាមគ្គីគ្នា នាំឲ្យខូចគំរោងការណ៍ប្រសើរនេះ ។

លោកតា ម៉ង់ និយាយចប់ ទើប ហ្នឹងឯក ក្រោកឈ*ឡើងពោលបន្តទៀត ៖

– តាមខ្ញុំយល់ ការតស៊ូរបស់យើង មានស្មើរគ្រប់ៗគ្នាទាំងអស់ ។ ប៉ុន្តែអ្នកខ្លះ

តស៊ូតែលើបបូរមាត់ក្រៅប៉ុណ្ណោះ តើមានប្រសិទ្ធិភាពអ្វីចំពោះសង្គ្រាមឈ្លានពានដូចសព្វថ្ងៃនេះ ?

ខ្ញុំនិយាយនេះ គ្មានគោលបំណងចង់ឲ្យប៉ះពាល់ដល់កិត្តិអស់លោកណាម្នាក់ទេ គឺនិយាយក្នុងន័យរកការពិតតែប៉ុណ្ណោះ ។ ប៉ុន្តែអស់លោកគួរតែយល់ឲ្យច្បាស់ថា «សម្បត្តិក្នុងផ្ទះដែលបាត់បង់ គឺព្រោះតែចោរក្នុងលួចប៉ុណ្ណោះយកទៅលាក់» ។

សម្ដីរបស់ ហ្វ៊ីនឯក ប៉ុន្មានប្រយោគនេះ ធ្វើឲ្យអង្គប្រជុំចាប់អារម្មណ៍យ៉ាងខ្លាំង ដោយពុំយល់ន័យដែលបង្កប់អាថ៌កំបាំងដ៏ស្មុគស្មាញនេះឡើយ ។ ភូឈ្មួយគង់ឱនមុខចុះមួយសន្ទុះក៏ក្រោកឈរឡើងបញ្ចេញផ្ទាំងមុខញញឹមយ៉ាងសោះកក្រោះហើយបោះសំដីដូចចោលដឹងទាំងដងង ៖

- លោក ហ្វ៊ីនឯក មានប្រសាសន៍អម្បាញមិញនេះចំជាត្រូវមែន ! តែនៅមិនទាន់ពេញលក្ខណៈពិតប្រាកដ ។ បើមិនយល់ទាស់ទេ ខ្ញុំសូមជួយថែមបន្តិចទៀតហើយសូមលោកកុំច្រឡំជើងលេខឲ្យសោះ ។ លោកយល់ហើយតើ សព្វថ្ងៃនេះមេទ័ពខ្មែរយើងមានទាន់បែកបាក់គ្នាឯណា ? ហេតុអ្វីក៏លោកលើកយកបញ្ហានេះមកចោទដើម្បីរំខានអង្គប្រជុំ ឲ្យបំបែកអារម្មណ៍ពីសង្គ្រាមឈ្លានពានរបស់យួនមកលើទីរួមខេត្តយើងទៅវិញ ?...

គួរឲ្យស្ដាយដែរ ! ដែលលោកខំបង្វែងដាន រឿងជាតិបញ្ចូលក្នុងរឿងផ្ទាល់ខ្លួនយ៉ាងនេះ ។

លោកតា ម៉ង់ ឮសំដីភូឈ្មួយ គង់ ខឹងញ័រសាច់ ក្រោកឡើងនិយាយកាត់សំដីឆ្លើយតបរបស់ហ្វ៊ីនឯកភ្លាម ៖

- ភាសាលោកភូឈ្មួយ ប្រហែលជាច្រឡំខ្ទង់លេខហើយ បានជាឆាប់ច្រឡោតខឹងមិនដឹងទិសតំបន់យ៉ាងនេះ ។ ធ្វើអ្វីក៏ដោយ ដើម្បីឲ្យបានជោគជ័យនោះ គេត្រូវតែនិយាយពីការរួបរួមសាមគ្គីផ្ទៃក្នុងសិន ទើបអាចយកជ័យជំនះលើសត្រូវបាន ។ លោក ហ្វ៊ីនឯក និយាយនេះ ក៏មិនខុសពីប្រសាសន៍លោកចៅហ្វាយ ដែលតែងពោលផ្ដែផ្ដាំជាញឹកញាប់ថា ៖ «សាមគ្គីគឺជាមហាគ្រឹះដ៏មាំក្នុងសង្គមជាតិ» នោះដែរ ។

ភូឈ្មួយ គង់ បើកភ្នែកធំត្រឡោតសម្លក់លោកតា ម៉ង់ ស្ទើរមិនព្រិចភ្នែកហើយស្ទុះក្រោកឡើងបំរុងនឹងឆ្លើយតបវិញតាមកំហឹងចិត្តក្ដៅ តែត្រូវលោកចៅហ្វាយធ្វើអន្តរាគមន៍បញ្ឈប់យ៉ាងស្ងៀមស្ងាត់ ។

⌘

⌘ ⌘

-៤-

# ឈាមហូរនៅទត្តផ្លូវដូង

សូមមិត្តបំបែរអារម្មណ៍ ទៅតាមដានពួកចោរប្លន់ទឹកដីម្ដងវិញ...

ក្រោយដែលបានទទួលជោគជ័យលើទីរួមខេត្តព្រះត្រពាំង ទ័ពយួនអុងឡូវវាសប្បាយចិត្តណាស់ បានរៀបចំពិធីជប់លៀងយ៉ាងគគ្រឹកគគ្រេង ហើយបញ្ជាបរិវារឲ្យដើរចាប់កូនក្រមុំរាស្ត្រខ្មែរ ដែលមានរូបស្អាតៗ មកជាន់ឈ្លីលេងជាល្បែងតាមអំពើយង់ឃ្នងព្រៃផ្សៃរបស់ពួកវា ។

រំលងបានមួយថ្ងៃមកទៀត វាចេញប្រកាសប្រាប់បណ្ដារាស្ត្រខ្មែរឃួនគ្រប់ភូមិស្រុក ឲ្យគោរពតាមច្បាប់ទម្លាប់របស់វា ហើយទទួលស្គាល់វាជាស្ដេចត្រាញ់ ក្នុងភូមិភាគដីកម្ពុជាក្រោមទាំងមូល ។ បើរាស្ត្រខ្មែរណាម្នាក់ហ៊ានក្រោកឡើងប្រឆាំងនឹងនយោបាយផ្ដាច់ការរបស់វា ប្រាកដជាត្រូវទទួលស្លាប់យ៉ាងអាណោចអធ័មពុំខាន ។

កាលនោះ ខ្មែរខ្លះដែលពួនមុខសម្ងំសុខ ក៏បិទមាត់លែងហ៊ាននិយាយស្ដីគឺបណ្ដោយឲ្យវាជាន់ឈ្លីតាមអំពើចិត្ត ។

ខ្មែរខ្លះ, ដែលមានស្មារតីស្នេហាជាតិ ក៏គៀសខ្លួនរត់ទៅចូលរួមជាសមាជិករបស់លោកសេនាបតី សឹន-គុយ ដើម្បីរៀបគំរោងការណ៍វាយតបនឹងចោរឈ្លានពានវិញ ។

រាល់ថ្ងៃទ័ពយួនអុងឡូវ តែងតែប្រើអំណាចព្រៃផ្សៃ ទៅលើប្រជាជនខ្មែរស្លូតត្រង់ ដោយកាប់សម្លាប់គ្មានញញើតដៃ ។ ឈាមក្រហមឆ្អៅហូរប្រឡាក់ពាសពេញផ្ទៃធរណីនៃទីរួមខេត្ត ។

ដំណឹងនេះ ធ្វើឲ្យលោកចៅហ្វាយ គុយ ខ្លោចផ្សាក្នុងចិត្តខ្លាំងណាស់ ប៉ុន្តែលោកដោះស្រាយឲ្យទាន់កាលៈទេសៈ ពុំបានយ៉ាងដាច់ខាត ពីព្រោះកម្លាំងទ័ពនៅទន់ខ្សោយពេក ពុំអាចវាស់ស្ទង់នឹងពួកវាបានឡើយ ។

លោកចៅហ្វាយគុយ បញ្ជាឲ្យលោកតា ម៉ង់ លោកហ៊ីនឯក លោកទេសាសោម និងលោកមនោរស់, ដើរអប់រំអ្នកស្រុកទាំងយប់ទាំងថ្ងៃ ឲ្យយល់ច្បាស់ពីរបបយោរយៅ និងចារិកសាហាវយង់ឃ្នងរបស់យួនអុងឡូវ លើរាស្ត្រខ្មែរម្ចាស់ស្រុក

ចំណែកភូឈួយ គង់ វិញ មិនរវល់អើពើនឹងបញ្ហាប្រទេសជាតិ ដែលកំពុងធ្លាក់ចុះក្នុងភាពអាសន្ននេះទេ ។ មួយថ្ងៃៗគាត់ដេករិះរកតែមធ្យោបាយ ដើម្បីស-

ម្លាប់តាម៉ង់ សងគំនុំចិត្តតែប៉ុណ្ណោះ ។ រីឯតាម៉ង់វិញ មានគំនិតផ្ទុយស្រឡះពីភូឈ្មួយគង់ ដូចមេឃនិងដី ។ ព្រោះសំដីដែលគាត់បានបើកកកាយ នៅចំពោះមុខលោកចៅហ្វាយ គុយ នោះ, គឺគ្មានបំណងអ្វីក្រៅពីចង់ឲ្យភូឈ្មួយ គង់ ងាកបែរដើរទៅរកផ្លូវត្រូវ ផ្លូវល្អនោះឡើយ ។

តាមឯកសារបានបញ្ជាក់ថា ភូឈ្មួយគង់ ជាមនុស្សពុករលួយក្នុងសង្គមខ្មែរ ចូលចិត្តរំលោភលើស្រីភេទទន់ខ្សោយ ឲ្យទទួលការឈឺចាប់ខ្លោចផ្សារាប់ស្មើមិនអស់ ។ មួយជំពូកទៀត ជននេះស្រឡាញ់បុណ្យស័ក្តិណាស់ ហើយយកបុណ្យស័ក្តិនោះទៅជិះជាន់សង្កត់សង្កិនអ្នកស្លូតត្រង់ទៀតផង ។

អំពើអនាថាទាំងប៉ុន្មានរបស់ភូឈ្មួយគង់, លោកចៅហ្វាយគុយ បានជ្រាបខ្លះដែរ ។ តែលោកចង់អប់រំមនុស្សខិលខូច ឲ្យស្គាល់កំហុសខ្លួនឯងដើរមករកផ្លូវត្រូវវិញ ទើបពុំមានដាក់ទណ្ឌកម្មធ្ងន់ធ្ងរអ្វី ចំពោះជនកំហូចនេះ ។

លោកចៅហ្វាយសឺន-គុយ ខំប្រើសង្គ្រាមចិត្តសាស្ត្រអប់រំ ទាហាននិងរាស្ត្រស្រែចំការ ពីបំណងរួម, គឺបណ្តេញទ័ពយួនឲ្យចេញផុតពីទឹកដីកម្ពុជាក្រោម ដែលជាមរតករបស់ខ្មែរ ។

លោកចៅហ្វាយគុយ រៀបចំកម្លាំងទ័ពបានមាំមួនបន្តិចហើយ ក៏ប្រើសង្គ្រាមវាយឆ្មក់ទ័ពយួនរាល់រាត្រី ដើម្បីរំខានវាមិនឲ្យដេកស្រណុកបាន ។

ឧបាយកលនេះ ធ្វើឲ្យមេទ័ពយួនអុងឡូវក្តៅក្រហាយក្រពុលមុខដូចឆ្កួតជ្រូក ចេញប្រកាសប្រាប់ពួកយួនគ្នាវាថា ៖ បើអ្នកណាម្នាក់អាចកាត់ក្បាលចៅហ្វាយគុ-យ ចាប់បានទាំងរស់ វានឹងឲ្យរង្វាន់តាមបំណង ហើយលើកតាំងជាមេទ័ពស្រួចលើដែនដីកម្ពុជាក្រោមនេះទៀតផង ។

ខណៈនោះ មានអាកន្ទបម្នាក់ឈ្មោះអុង បូ ស្ម័គ្រចិត្តចេញមុខរកឧកញ៉ាគុយ ដើម្បីកាត់ក្បាលយកមកជូនលោកមេទ័ពអុងឡូវ ។

បានទទួលការតែងតាំងជាមេទ័ពហើយ អុងបូក៏នាំពលទាហានមួយចំនួនធំ ធ្វើដំណើរយ៉ាងគគ្រឹកគគ្រេង តម្រង់ឆ្ពោះទៅវត្តផ្នូរដូង ដែលជាទីតាំងទ័ពរបស់លោកចៅហ្វាយគុយតែម្តង ។

មេទ័ពខ្មែរទាំងអស់បានប្រុងប្រៀបខ្លួនជាស្រេច ។ គ្រាន់តែក្រឡេកឃើញទ័ពយួនមកដល់ភ្លាម ក៏បញ្ជាទាហានឲ្យវាយទប់យ៉ាងបន្ទាន់ ។ ការប្រយុទ្ធបង្ហូរឈាមលើកនេះ មានសភាពសាហាវនិងឃោរឃៅណាស់ ។ មេទ័ពខ្មែរម្នាក់ៗ សុទ្ធតែប្តូរស្លាប់រស់ រត់ចូលទៅក្របែលក្បាលយួន ដាច់ពីស្មាធ្លាក់រពុយរលំដួល ដូចរលើងដើមឈើទាំងឫស ។

ទោះបីឃើញពលសេនាងាប់ គរជើងលើគ្នាដូចដំបូក ក៏អុងបូមិនព្រមដកទ័ព

ថយដែរ គិតវែស្រែកបញ្ជាឲ្យចូលកាប់សម្លាប់ខ្មែរ សូម្បីតែព្រះសង្ឃក៏វាពុំទុកឲ្យរស់នៅបានមួយដង្ហើមឡើយ ។

ការប្រយុទ្ធនេះបានប្រព្រឹត្តទៅអស់ពេលជាច្រើនយប់ច្រើនថ្ងៃ ។ ទ័ពយួនចេះតែមានជំនួយបន្តកន្ទុយគ្នាមិនចប់ ។ ចំណែកឯខាងខ្មែរយើងវិញ កាន់តែរលស់បន្តិចម្តងៗ ដោយពុំមានព្រះមហាក្សត្រចាត់ទ័ពឲ្យទៅជួយស្រោចស្រង់សោះ ។ ព្រឹត្តិហេតុទាំងនេះ ធ្វើឲ្យលោកចៅហ្វាយគុយនឹកសង្វេគក្នុងចិត្តយ៉ាងខ្លាំង តែពុំអាចនឹងថ្លែងប្រាប់ជនទី២ណាបានឡើយ ។

ស្ថានការណ៍ធ្ងន់ពាប់ផ្ទួនៗគ្នា ពុំអាចនឹងទប់ទល់បាន, លោកចៅហ្វាយគុយក៏បញ្ជាឲ្យមេទ័ពទាំងអស់វាយដកខ្លួនថយតាមក្បួនយុទ្ធសាស្ត្រមួយរយៈទៀត ដើម្បីរង់ចាំទ័ពជំនួយពីខេត្តនានា ។

ទ័ពយួនកាលបើឃើញខ្មែរខ្សោយកម្លាំងដូច្នេះ ចារីតតែវាយបង្ហំខ្លាំងឡើងៗ ដើម្បីព័ទ្ធចាប់ចៅហ្វាយគុយឲ្យបានទាំងរស់ យកទៅជូនអុងឡូវជាចៅហ្វាយនាយរបស់វា ។

ហ្វឹនឯក យល់ហេតុការណ៍ ស្ទុះរឹងទៅតាំងមុខទ័ពយួន រួចលូកដៃទៅក្នុងថ្នក់ចាប់ស្រូវមួយក្តាប់យ៉ាងណែន សូត្រគាថាបាចបញ្ជោសខ្យល់ កើតជាទ័ពសេះមួយចំនួន ឈរត្រៀបត្រារាំងផ្លូវសត្រូវជាប់ ។ បន្ទាប់មកមេទ័ពដ៏ជំនាញនេះហក់រឹងទៅខាងឆ្វេង ចាប់ក្របួចចុងស្មៅក្ងួចចងជាច្រើនកន្លែង បង្កើតបានជាពលសេនាប្រដាប់ដោយដាវលំពែងឈរជាជួរ តាមលក្ខណៈយុទ្ធសាស្ត្រ ពួកយួនឃើញដូច្នោះ នឹកឆ្ងល់និងភ័យលោះព្រលឹង ។ ព្រោះការប្រយុទ្ធគ្នានៅក្នុងវត្តផ្នូរដូងអំបាញ់មិញនេះ ទ័ពខ្មែរមានតិចតួចស្តួចស្តើងណាស់ ។ ឥឡូវម្តេចក៏ច្រើនកកស្រទាប់ឈរតម្រៀបក្បាលគ្នាដូចស្រមោចយ៉ាងហ្នឹង ?...

មេទ័ពអុងបូ យកដៃឈ្លីភ្នែកមួយសន្ទុះ ក៏ស្រែកពលទាហានឲ្យចូលកាប់ចាក់យ៉ាងបន្ទាន់ ។ ទ័ពយួនចូលប្រឡូកកាប់សម្លាប់ទ័ពសិល្បរបស់ហ្វឹនឯក រលំដួលលាន់ស្នូរដូចរលើងដើមឈើទំហំ៧អោប តែគ្មានឃើញខ្មោចទាហានខ្មែរម្នាក់សោះ ។

មេទ័ពអុងបូ នឹកមួរម៉ៅក្តៅក្រហាយខ្លាំងណាស់ ចំកោងខ្នងស្រែកបញ្ជាទ័ពឲ្យវាយលុកមួយសន្ទុះធំទៀត រហូតបែកញើសហូរសស្រាក់ជោកខ្លួន ស្រាប់តែទ័ពសិល្បរលាយបាត់ស្រមោលអស់រលីង ។ បន្ទាប់មកវាក៏បំបែរក្បាលទ័ពត្រឡប់ទៅបោះជំរំឈប់សំរាក នៅក្នុងបរិវេណវត្តផ្នូរដូងវិញ ។

ពួកចោរឈ្លានពានបានលុកទន្ទ្រាន កាប់គាស់បំផ្លាញកុដិព្រះសង្ឃ និងទ្វារបង្អួចព្រះវិហារ រើយកគម្ពីរព្រះពុទ្ធសាសនា និងក្បួនមាត្រាអក្សរសាស្ត្រខ្មែរដុតកំ-

ទេចចោលយ៉ាងច្រាស់ជើង ដើម្បីលប់បំបាត់អក្សរសាស្ត្រជាតិរបស់យើង ។

បើងាកទៅតាមដាន លោកចៅហ្វាយគុយវិញម្តង ឃើញគាត់កំពុងតែទទួលការឈឺចាប់ខ្លោចផ្សា នាំពួកពលសេនារត់កាត់ព្រៃ ឆ្ពោះទៅរកទីដៅមួយថ្មីទៀត ។ គាត់ដើរបណ្តើរនិយាយលួងចិត្តកងទ័ពបណ្តើរ ដើម្បីកុំឲ្យខូចទឹកចិត្ត នឹងការទទួលបរាជ័យដ៏ជូរចត់នេះ ។ គឺគាត់សង្ឃឹមថា ថ្ងៃណាមួយគង់តែកូនខ្មែរទាំងអស់ ភ្ញាក់ស្មារតីឡើង កាន់កាំបិតពូថៅ កាប់ក្បាលពួកសត្រូវប្រទេសជាតិ ឲ្យវិនាសផុតពូជជាពុំខាន ។

គាត់នាំកងទ័ពដើរអស់រយៈមួយយប់ពីរថ្ងៃ ទើបបានទៅដល់វត្តចេតិយដែលជាវត្តខ្មែរមានបរិស័ទចំណុះជើងវត្តជាច្រើន ។

វត្តចេតិយមានបណ្តោយប្រវែងជាង២០០ម៉ែត្រ ទទឹងប្រហែល២០០ម៉ែត្រ ។ ក្នុងវត្តមានព្រះសង្ឃបួសកាន់ព្រះពុទ្ធសាសនាចំនួន៥០អង្គ ។

តាមឯកសារ វត្តចេតិយនេះជាកេរ្តិ៍តំណែលរបស់លោកចៅហ្វាយគុយ ដែលបានផ្តើមគំនិតកសាងឡើង រួមជាមួយនឹងពួកពុទ្ធបរិស័ទចំណុះជើងវត្ត ដើម្បីឧទ្ទិសកុសលថ្វាយចំពោះព្រះពុទ្ធសាសនា ។

លោកចៅហ្វាយ សឺន-គុយ ជាវីរបុរសខ្មែរម្នាក់ ស្អាតស្អំក្នុងរឿងតណ្ហា កាលគាត់នៅពីកម្លោះ, មានជនជាតិយួនជាច្រើននាក់ បានលើកកូនក្រមុំយកមកជូនគាត់រាប់ក្បាលស្ទើរមិនអស់ តែគាត់មិនព្រមយកជាដាច់ខាត ទោះបីវាប្រើគ្រប់មធ្យោបាយយ៉ាងណាក៏ដោយ ។ គាត់បានចាំដក់ជាប់ក្នុងខួរក្បាលជានិច្ចថា សត្រូវយួននិងខ្មែរពិតជាពុំមានថ្ងៃនឹងបញ្ចប់បានឡើយ ។

កន្លងជាច្រើនឆ្នាំមកទៀត លោកក៏យល់ថា ការរស់នៅម្នាក់ឯងគ្មានប្រពន្ធកូនប្រៀបបាននឹងផ្ទះគ្មានជញ្ជាំងបិទបាំង ឬដំណើរគ្មានទិសដៅ ។ ដូច្នេះគាត់ក៏សំរេចចិត្តជាចុងក្រោយថា ត្រូវតែរកគ្រួសារដើម្បីកសាងអនាគតដ៏រុងរឿង ។

លោកឧកញ៉ាបានពឹងពាក់អ្នកចាស់ទុំ ក្នុងទីរួមខេត្តព្រះត្រពាំង ឲ្យចូលទៅស្តីដណ្តឹងនាងកញ្ញា ភឿន ដែលជាកូនកសិករស្លូតត្រង់ម្នាក់ នៅក្នុងភូមិចាប់ភ្លើងនាជើងវត្តរបងចេតិយ ធ្វើជាភរិយារហូតទៅ ។

ដូច្នេះហើយ នៅពេលលោកចៅហ្វាយគុយ នាំទ័ពទៅដល់វត្តចេតិយភ្លាម, គាត់ក៏ចូលទៅសំពះអនុញ្ញាតព្រះគ្រូចៅអធិការ សុំឲ្យកងទ័ពស្នាក់អាស្រ័យនៅក្នុងទីវត្តជាបណ្តោះអាសន្នសិន ទំរាំរកមូលដ្ឋានបានត្រឹមត្រូវ រៀបគំរោងការណ៍វាយបណ្តេញសត្រូវឈ្លានពានពីទឹកដីខ្មែរ ។

ក្រោយពេល ដែលបានទទួលសេចក្តីយល់ព្រមពីព្រះគ្រូចៅអធិការហើយ, លោកចៅហ្វាយគុយ អញ្ជើញចូលទៅក្នុងព្រះវិហារទៀត ដើម្បីថ្វាយបង្គំព្រះពុទ្ធ-

ប្បដិមា ដែលជាតំណាងព្រះពុទ្ធជាម្ចាស់ សុំជ្រកកោនក្រោមម្លប់បារមីព្រះអង្គ និងសុំជីកដីកប់អាវុធលាកទុកជាបណ្តោះអាសន្ន កុំឲ្យពួកសត្រូវយួនតាមរកឃើញ ។

បន្ទាប់មកគាត់បានប្រមូលអ្នកស្រុក មករួមប្រជុំបង្កើតជាគណៈកម្មការភូមិនិងអ្នកដើរឃោសនា ណែនាំពន្យល់អប់រំបងប្អូនខ្មែរទាំងអស់ ឲ្យស្គាល់តម្លៃនៃព្រះពុទ្ធសាសនា ឲ្យគោរពព្រះពុទ្ធសាសនា ព្រោះព្រលឹណពុទ្ធសាសនាជាអង្គការធំបំផុតក្នុងការបង្រួបបង្រួមគ្នា ឲ្យសាមគ្គីចងបាច់ជាធ្លុងមួយ ។

លោកចៅហ្វាយគុយ បាននិយាយដាស់តឿនក្រើនរំឭកប្រជាពលរដ្ឋ ឲ្យបំផុសស្មារតីតស៊ូ ចាប់កាន់អាវុធក្រោកឡើងដើម្បីការពារភូមិស្រុក ដេញកំចាត់ចោរយួនប្លន់ប្រទេស ឲ្យវិនាសអស់ក្នុងពេលឆាប់ៗនេះ ។

វិធានការដ៏ត្រជាក់របស់លោកចៅហ្វាយគុយ ពឹងផ្អែកទាំងស្រុងទៅលើព្រះពុទ្ធសាសនាជាមូលដ្ឋាន បានផ្សព្វផ្សាយគ្រប់ភូមិស្រុកទាំងអស់ បណ្តាលឲ្យរាស្ត្រខ្មែរទាំងប្រុសស្រីភ្ញាក់ស្មារតី ចេះឈឺចាប់ រត់ចូលមករួមកម្លាំងគ្នាជាមួយចៅហ្វាយគុយជាបន្តបន្ទាប់រៀងរាល់ថ្ងៃ ។ អ្នកខ្លះដែលមានទ្រព្យសម្បត្តិច្រើន បានធ្វើវិភាគទានទូនកងទ័ពជាតិដោយចិត្តស្មោះសជ្រះថ្លាជាទីបំផុត ។

ក្នុងរយៈពេលតែមួយខែប៉ុណ្ណោះ កងទ័ពលោកចៅហ្វាយគុយត្រូវកើនមួយជាពីរ ហើយមិនខ្វះស្បៀងអាហារចិញ្ចឹមទ័ពទៀតផង ។ លោកបានចាត់មេបញ្ជាការ និងគ្រូគន់ដាវដំបងជាច្រើននាក់ ឲ្យបង្ហាត់ពលទាហានដែលទើបនឹងស្ម័គ្រចិត្តចូលមកថ្មី ដើម្បីឲ្យចេះក្បួនយុទ្ធសាស្ត្រ វាយលុកលួនក្រាបក្នុងសង្គ្រាម ។ ស្រីៗនាំគ្នាសំរួចដាវលំពែង បឹតព្រួញទាំងយប់ទាំងថ្ងៃគ្មានខ្ជិលច្រអើយហត់ រហូតបានទទួលលទ្ធផលគរដូចភ្នំ ។

ងាកមើលទៅទ័ពលោកអន្សាសោម និងមនោរស់ ដែលចេញប្រតិបត្តិការរាល់ថ្ងៃ បានលួចវាយឆ្មក់ទ័ពសត្រូវបុំមានឈប់ឈរឡើយ ។រីឯលោកហ្សឹនឯកនិងតាម៉ង់ ដែលមានទឹកមុខក្រៀមស្រពោន ដោយឈឺចាប់នឹងសង្គ្រាមបរាជ័យរបស់ខ្លួន មកមួយខែហើយនោះ ពេលនេះហាក់មានកម្លាំងបន្តិចឡើងវិញ ព្រោះឃើញកងទ័ពខ្មែរយ៉ាងច្រើនកុះករ កំពុងបញ្ចេញសកម្មភាពរស់រវើក ដើម្បីប្រឆាំងទប់ទល់នឹងសត្រូវរួម ។

តាម៉ង់ សម្លឹងមើលពលទាហានមួយគ្រួស រួចងាកមកញញឹមដាក់ហ្សឹនឯក ព្រមទាំងបន្លឺវាចាដោយរន្ធត់ចិត្ត ៖

- លោកហ្សឹនឯកខ្ញុំស្តាយណាស់ ដោយវិធានការណ៍របស់យើងយឺតយូរបន្តិច ទើបពួកសត្រូវវាចូលលុកលុយពាសពេញស្រុកយើងយ៉ាងនេះ ។ ម៉្យាងទៀតទ័ពរដ្ឋាភិបាលមកជួយយើងក៏មិនកើតដែរ ព្រោះយួនវាបានវាយស្កាត់ផ្លូវរួចស្រេច

ទៅហើយ ម្តងនេះយើងពិបាកសង្ឃឹមណាស់ ។ ភូមិភាគដែនដីកម្ពុជាក្រោមទាំងមូល យួនវាយកបានស្ទើរតែគ្រប់កន្លែងអស់ទៅហើយ ។ ប៉ុន្តែ បើបងប្អូនខ្មែរយើងចេះរួបរួមសាមគ្គីគ្នាដូចពេលនេះរហូតទៅ ខ្ញុំនៅតែសង្ឃឹមនឹងជឿជាក់ថា យើងប្រាកដជាអាចរំដោះយកខេត្តព្រះត្រពាំងបានមកវិញមិនខាន ។

លោកហ៊ីនឯកងក់ក្បាលដាក់តាម៉ង់ ហើយចោលកន្ទុយភ្នែកសម្លឹងមើលទៅជើងមេឃឆ្ងាយដាច់សង្វែង ហាក់បញ្ជាក់ន័យថាសេចក្តីសង្ឃឹមមានប្រាកដមែន តែស្ថិតនៅឆ្ងាយសន្ធឹមណាស់ ។

មួយសន្ទុះធំ ទើបហ៊ីនឯកបន្ទរខ្យល់អួលអាក់ចេញពីផៃទ្រូង រួចពោលពាក្យមួយម៉ាត់ៗយ៉ាងច្បាស់លាស់ទៅកាន់មិត្តចិត្តមួយ ៖

- ខ្ញុំមិនត្រឹមតែស្តាយស្រណោះប៉ុណ្ណោះទេ...ក្នុងមួយជីវិតខ្ញុំនេះ ខ្ញុំទទួលការឈឺចាប់ផ្ទួនៗគ្នាហួសប្រមាណ ។ ចិត្តខ្ញុំចង់ច្បាំងជាមួយយួនតែម្នាក់ឯង ទោះបីត្រូវស្លាប់ដូចសត្វពន្លាត់ ក៏ខ្ញុំមិនស្តាយដែរ ព្រោះឆាកជីវិតរបស់ខ្ញុំជួរចត់តាំងពីក្មេងមក ។ កាលណោះ គ្រាន់តែខ្ញុំដឹងក្តីឡើងភ្លាម ចោរយួនវាបានសម្លាប់គ្រួសារខ្ញុំអស់មួយផ្ទះ សូម្បីតែប្អូនស្រីរបស់ខ្ញុំដេកក្នុងអង្រឹង ក៏វាមិនទុកឲ្យរស់រានជីវិតដែរ។ ដោយខ្ញុំទទួលការឈឺចាប់នឹងអំពើយង់ឃ្នងរបស់វាដូច្នេះហើយ បានជាខ្ញុំស្ម័គ្រចិត្តចូលធ្វើទាហានតាំងពីអាយុ១០ឆ្នាំម្ល៉េះ ។ តាំងពីនោះរហូតមកដល់ពេលនេះ ខ្ញុំធ្លាប់ចូលប្រឡូកក្នុងសង្គ្រាមរាប់មិនអស់ទេ ហើយក៏ពុំដែលត្រូវរបួសម្តងណាផង ។ ឥឡូវនេះ ទឹកចូលដល់ច្រមុះយើងហើយ ទោះបីមួយជំហានស្លាប់ ក៏ខ្ញុំមិនរាថយដែរ ។

លោកតាម៉ង់ ខ្ញុំយល់ឧត្តមគតិ និងទឹកចិត្តស្នេហាជាតិរបស់លោកយ៉ាងពិតប្រាកដណាស់ ហេតុនេះយើងទាំងពីរនាក់ត្រូវតែរួមដៃប្តូរស្លាប់រស់ជាមួយគ្នា ។ ខ្ញុំសង្ឃឹមថា ផែនការសម្ងាត់របស់យើង ដែលបានបង្កប់គ្រប់ទីកន្លែងនោះ ប្រាកដជាបានជោគជ័យពុំខាន ។

តាម៉ង់គ្រវីក្បាលមួយៗដូចអស់សង្ឃឹម ហើយពោលពាក្យបញ្ជាក់ប្រាប់ហ៊ីនឯកម្តងទៀត ៖

- លោកហ៊ីនឯកនិយាយអម្បាញមិញនេះត្រូវណាស់ ! ប៉ុន្តែនៅមានចំណុចខ្លះ ដូចដែលខ្ញុំធ្លាប់និយាយប្រាប់លោក តាំងពីដើមរឿងមកថា គំរោងការណ៍សម្ងាត់របស់យើង បែកធ្លុះធ្លាយទៅបាន ក៏ដោយសារតែមនុស្សម្នាក់ប៉ុណ្ណោះ ដូចលោកជ្រាបស្រាប់ហើយ ។

ប៉ុន្មានថ្ងៃចុងក្រោយនេះ ខ្ញុំឃើញទឹកមុខលោកចៅហ្វាយយើងស្រងូតស្រងាត់ ហើយដល់ខ្ញុំលួចសួរគាត់ទៅ គាត់បានខ្សិបប្រាប់ខ្ញុំថាយួនបានដឹងផែនការណ៍

សម្ងាត់របស់យើងច្រើនណាស់ ហើយវាចាត់ការទប់ទល់យ៉ាងបន្ទាន់ផង ។
លោកហ្មឺនឯកភ្ញាក់ខ្លួនព្រើតដូចគេចាប់កន្ត្រាក់ បញ្ជាក់សួរតាម៉ង់ថា ៖
- លោកចៅហ្វាយដឹងពត៌មាននេះពីណាមក ?
- ហឺ ! គឺដឹងពីអ្នកយកការណ៍សម្ងាត់របស់យើងណា៎ ! បើតាមខ្ញុំស្មានប្រាកដជាមិនខុសទេ, ប៉ុន្តែនិយាយប្រាប់គេ គ្មានអ្នកណាយកចិត្តទុកដាក់សោះ ។ ពេលឲ្យខ្លី បើយើងមិនសម្លាប់ភូឈ្មួយគង់ ក្នុងកាលៈទេសៈនេះទេ យើងប្រាកដជាត្រូវទទួលបរាជ័យគ្រប់សមរភូមិហើយ ។ តើយើង គួរទុកមនុស្សម្នាក់ឲ្យរស់ ដើម្បីជាតិស្លាប់ ?... ឬក៏សម្លាប់មនុស្សម្នាក់ ដើម្បីជាតិរស់ ?... ។
លោកហ្មឺនឯក ឃើញភ្លើងកំហឹងតាម៉ង់ឆេះពុះពោរដល់ក៏រឹត គាត់ក៏ឱនមុខចុះសញ្ជឹងគិតមួយសន្ទុះ ទើបនិយាយ ៖
- គំនិតដ៏ខ្មៅក្រខ្វក់របស់ភូឈ្មួយគង់ ខ្ញុំដឹងខ្លះៗដែរ តែរកចាប់ភស្តុតាងពិតប្រាកដមិនទាន់បាន ។ ដូច្នេះ បើយើងសម្លាប់ភូឈ្មួយគង់ ក្នុងពេលនេះភ្លាមៗទៅក្រែងនាំឲ្យមានការស្តាយក្រោយ ។ ប៉ុន្តែ បើថ្ងៃណាយើងចាប់បានឯកសារជាក់ស្តែងរបស់វាហើយ គឺយើងមិនទុកវាហើយ គឺយើងមិនទុកវាឲ្យរស់បានមួយដង្ហើមយ៉ាងដាច់ខាត ។
តាម៉ង់ដកដង្ហើមធំលាន់ឮ ហើយពន្យល់ហ្មឺនឯកថែមទៀត ៖
- មនុស្សលាក់ពុត ត្រាំពិសស៊ីរូងផ្ទៃក្នុងរបៀបភូឈ្មួយគង់នេះ យើងពិបាកនឹងចាប់ភស្តុតាងរបស់វាបានជាក់ស្តែងណាស់ ព្រោះវាជាឆ្មាលាក់ក្រចក យកការលុតក្រាបជាត្រីមុខ ។ កាលពីថ្ងៃមុន វាបានប្រឌិតពាក្យមួលបង្កាច់យ៉ាងឧក្រិដ្ឋជំរាបលោកឧកញ៉ាថា ខ្ញុំប្រមាថមើលងាយបុណ្យស័ក្តិរបស់វា ហើយចង់សម្លាប់វាខោលទៀត ។ ពេលនោះបើកុំតែ លោកឧកញ៉ាយល់ច្បាស់ ពីទឹកចិត្តស្មោះត្រង់របស់ខ្ញុំចំពោះជាតិ កុំអីប្រហែលជាស្លាប់ដោយអយុត្តិធម៌ទៅហើយ ។ សូមលោកហ្មឺនឯកជួយកត់ត្រានឹងចាំជាក់ក្នុងចិត្តចុះ បើខ្ញុំមិនស្លាប់ក្នុងសង្គ្រាមទេ ថ្ងៃណាមួយក៏ត្រូវតែស្លាប់ ដោយបាតដៃប្រឡាក់ឈាមរបស់ភូឈ្មួយគង់ដែរ ។ សព្វថ្ងៃនេះវាកំពុងតែ ស្ថិតក្នុងលក្ខណៈជាខ្លាចាស់ចាំសីលយ៉ាងប្រាកដ ។
លោកហ្មឺនឯកនិងតាម៉ង់ កំពុងតែវែកញែកអាថ៌កំបាំង ឆ្អឹះរកក្រយៅក្បត់របស់ភូឈ្មួយគង់ ស្រាប់តែមានទាហានម្នាក់ ដើរចូលមកជំរាបថា ៖
- ព្រះតេជគុណ ! លោកឧកញ៉ា សូមអញ្ជើញព្រះតេជគុណទៅជួបជាប្រញាប់ ព្រោះមានរឿងសំខាន់ណាស់ទានប្រោស !
លោកហ្មឺនឯកនិងតាម៉ង់ស្តាប់ឮហើយ ក៏ប្រញាប់នាំគ្នាដើរឆ្ពោះទៅជំរំ លោកឧកញ៉ាជាបន្ទាន់ ។

លោកឧកញ៉ាឃើញសេនាជំនិតទាំងពីរនាក់មកដល់ ក៏មានប្រសាសន៍ទាំងទន់ភ្លន់ថា ៖

- តាមពត៌មានពីអ្នកស៊ើបការណ៍សម្ងាត់របស់យើង បាមឲ្យមកអម្បាញ់មិញនេះបញ្ជាក់ថា ទ័ពឃ្មួនអុងបូ ដែលបោះជំរំនៅវត្តផ្ទូរដូងនោះ វាកំពុងតែរៀបចំពិធីជប់លៀងមួយយ៉ាងគគ្រឹកគគ្រេង ដើម្បីរំលឹកថ្ងៃជោគជ័យរបស់វា លើទឹដីរួមខេត្តព្រះត្រពាំងយើង ។ វានាំគ្នាស្រែកហោរកញ្ជៀវទ្រហឹងអឺងកង ចូលរុកទន្រ្ទានក្នុងព្រះវិហារ វាយកំទេចព្រះពុទ្ធប្បដិមា (១) ហើយយកដែកបោះក្នុងព្រះឧស្ធព្រះអង្គធំ រួចយកឆ្អឹង ឆ្កែ ឆ្មា គោ ក្របី ទៅចងព្យួរណែងរណោង ក្នុងន័យមើលងាយព្រះពុទ្ធសាសនាយើងជាទីបំផុត ។ ឥឡូវនេះ យើងត្រូវតែរកមធ្យោបាយ ដោះស្រាយឲ្យទាន់ពេលវេលា ។

តាម៉ង់ស្តាប់ប្រសាសន៍លោកឧកញ៉ាចប់ ភ្លើងកំហឹងឆេះឆួលដល់កម្រិត ស្ទុះក្រោកឡើងបញ្ចេញយោបល់ភ្លាម ៖

- អំពើព្រៃផ្សៃរបស់ពួកវា ក្នុងខណៈនេះ មិនអាចអត់ទ្រាំតទៅទៀតបានទេ ដាច់ខាតត្រូវតែលើកទ័ពទៅកំទេច ឲ្យវិនាសក្នុងពេលជាបន្ទាន់នេះ ។

តាម៉ង់និយាយចប់ ហ្មឺនឯកក៏បន្ថែមទៀត ៖

- តាមគំនិតខ្ញុំ គឺត្រូវតែអនុវត្តតាមយោបល់របស់លោកតាម៉ង់ ព្រោះពេលនេះវាកំពុងតែស៊ីផឹកស្រវឹងភ្លេចខ្លួន យើងអាចវាយសន្ធាប់យកជ័យជំនះបានដោយងាយ ។ បើព្រឹត្តិការណ៍រុញមកឲ្យហើយ ហើយយើងមិនព្រមអនុវត្តនោះ ថ្ងៃក្រោយប្រាកដជាពុំអាចរកកាលៈទេសៈដ៏ល្អនេះបានទៀតទេ !

យោបល់របស់លោកមេទ័ពទាំងពីរ ធ្វើឲ្យលោកចៅហ្វាយគុយពេញចិត្តខ្លាំងណាស់ ។ លោកញញឹមក្នុងន័យសង្ឃឹម ហើយងាកទៅរកភូឈ្មួយគង់ រួចបញ្ជាក់ថា ៖

- លោកភូឈ្មួយ ! សូមលោកប្រញាប់ធ្វើសារមួយ ផ្ញើដំណឹងទៅជូនលោកទេសាសោម និងលោកមនោរស់ ឲ្យបានជ្រាបពីដំណឹងនេះផង ព្រោះទ័ពយើងត្រូវចេញដំណើរឆ្ពោះទៅវត្តផ្ទូរដូង ក្នុងពេលឥឡូវនេះហើយ ។

ចប់បញ្ជាលោកឧកញ៉ា ហ្មឺនឯកនិងតាម៉ង់ ក៏ចាកចេញពីអង្គប្រជុំទៅកាន់ជំរំទ័ពរៀងៗខ្លួន ដើម្បីប្រមូលទ័ពចេញដំណើរទៅកាន់សមរភូមិ ។

លោលឧកញ៉ារៀបចំគ្រឿងសាស្ត្រាវុធ និងផ្លាស់សំលៀកបំពាក់រួច កងទ័ពក៏ស្រែកហោរកញ្ជៀវបីដង ដើម្បីប្រសិទ្ធិពរជ័យ ហើយចេញដំណើរយ៉ាងស្វាត់

---

*(១) ច្បាប់ដើមសរសេរ ព្រះពុទ្ធដិមាករ ។ បដិមា ប្រែថារូបសំណាក, បដិមាករ អ្នកធ្វើរូបសំណាក ។*

ស្មៀមឆ្ពោះទៅរកទិសដៅ ។

តាមឯកសារបញ្ជាក់យ៉ាងច្បាស់ថា នៅពេលដែលកងទ័ពស្នេហាជាតិខ្មែរយើងធ្វើដំណើរទៅជិតដល់ជំរំចោរយួនអុងបូ ដែលតាំងនៅក្នុងបរិវេណវត្តផ្នូរដូងនោះ ស្រាប់តែមេឃមីរងងឹត ខ្យល់ព្យុះបក់បោកយ៉ាងខ្លាំង រន្ទះបាញ់កក្រើកប្រថពី ភ្លៀងបីមេយ៉ាងធំបង្អុរចុះមក ទាំងកណ្ដាលខែប្រាំងក្ដៅហួតហែង ។ ហាក់ដូចជាទសបារមីនៃព្រះអង្គវត្តផ្នូរដូងដាក់បណ្ដាសាដល់ពួកចោរប្លន់ទឹកដី ដែលចូលជាន់ឈ្លីវត្តអារាម ដុតបំផ្លាញព្រះពុទ្ធសាសនាដ៏ជាទីគោរពរបស់ខ្មែរយើង ។

លោឧកញ៉ាមិនទុកពេលឲ្យពួកចោរយួនដឹងខ្លួនទាន់ឡើយ ។ គាត់ក៏បញ្ជាទ័ពឲ្យវាយលុកជាបន្ទាន់ ។

ទ័ពយួនដែលស្រវឹងស្រា ដួលដេកគរជើងលើគ្នា ដូចសត្វធាតុនោះ ក្រឡេកឃើញទ័ពខ្មែររត់សំរុកចូលទៅ ក៏ខំក្រោកប្រវេប្រវាចាប់អាវុធ ប្រយុទ្ធតទល់ទាំងប្រថុយស្បៃក ។

ចំណែកមេទ័ពអុងបូវិញ ឃើញទាហានខ្មែរបញ្ចេញអាកប្បកិរិយាអង់អាច កាប់សម្លាប់ពលសេនារបស់វាស្លាប់ដូចគេហាល ឈាមហូរឆ្អាបហួងស្ទើរទប់កំអួតពុំបាននោះ ក៏ភ័យស្លាំងមុខស្វាងស្រាមួយរំពេច ។

លោកហ្វឹនឯកនិងតាម៉ង់ មិនបង្អង់ដៃឲ្យខាងពេលវេលាទេ គេនាំគ្នាបង្វើរផ្លែដាវដ៏មុត កាត់ផ្ដាច់ក្បាលចោរយួនពីមួយទៅមួយ ដាច់ធ្លាក់ពីស្មាជ្រុះរពុយរាប់កន្លះថ្ងៃស្ទើរមិនអស់ ។

មេទ័ពរបស់អុងបូក្រឡេកឃើញហ្វឹនឯកសាហាវដូចខ្លាត្រូវរបួស ក៏ហូតដាវហក់ផ្លាញមកពីចម្ងាយ ហើយយាកាប់វីបៗពុំបង្អង់ដៃ ដើម្បីប្រល័យមេទ័ពខ្មែរដ៏កំពូលនេះ ។

តាម៉ង់ក្រឡេកឃើញទាន់លោតវឹងពីចម្ងាយយារដាវ បញ្ឆោតឆ្វេងកាប់ស្ដាំវីបៗពីរដងផ្ទួនៗគ្នា ដងខ្លួនមេទ័ពរងអុងបូត្រូវដាច់ជាពីរកំណាត់ស្លាប់តែហោងភ្លាមមួយរំពេច ។

អុងបូក្រឡេកឃើញមេទ័ពរង ស្លាប់ដូចសត្វពន្លាត់យ៉ាងនេះភ័យញ័រខ្លួនទទ្រើក រត់ឆ្លេឆ្លាបំរុងរកច្រកដាក់មេផាយប្រាសអាយុ តែលោកចៅហ្វាយគុយក្រឡេកឃើញទាន់ ក៏ស្ទុះវឹងដេញតាមកិតពីក្រោយ ។ អុងបូយល់ស្ថានការណ៍ធ្ងន់ពាប់ ដែលពុំអាចរំដោះខ្លួនរួច ក៏បែរមុខមកបញ្ចេញចង្កូមកាចសហាវដាក់លោកឧកញ៉ា ហើយយារដាវគ្រវីវិលខ្វាល់កាប់ផ្ទួនៗគ្នាពុំឈប់ឈរ ។

លោកឧកញ៉ាបញ្ចេញក្បាច់យុទ្ធសាស្ត្ររហ័សដូចផ្លេកបន្ទោរ គ្រវីដាវឃើញតែពន្លឺសព្រាតៗ បង្ខំឲ្យមេទ័ពយួនលោតគេចវក់វីហាត់គយូរ ដកងង្ហើមស្ទើរពុំដល់

គ្នា ។

ដោយពុំអាចទប់ទល់នឹងកម្លាំងដាវរបស់លោកឧកញ៉ាបាន មេទ័ពយួនត្រចៀកស ក៏រត់បោះពួយលឿនស្លៅសំដៅទៅមុខព្រះវិហារ តែទោះជាយ៉ាងណាក៏ប្រមុខខេត្តព្រះត្រពាំងមិនអនុញ្ញាត ឲ្យវារត់រួចយ៉ាងដាច់ខាត ។ លោកប្រញាប់រត់វឹងតាមពីក្រោយ ហើយយារដាវកាប់វឹបៗ ត្រូវស្នាអុងបូ ដាច់សាច់ហូរឈាមមកកក្លាក់ដូចអារកមាន់ ។ ជនអសិរពិសឈឺចាប់ខ្លាំងណាស់ ក៏ងាកមកចាក់តបតវិញទាំងកម្រោលប្អូនជ្រូង ។

លោកឧកញ៉ាឃើញខ្លាចង្កមរិល កំពុងតែត្រដរខ្យល់រកស្លាប់ គាត់ក៏ប្រញាប់លោតហាល់ថយក្រោយមួយជំហាន យារដាវកាប់ពីក្រោយរះឡើងលើ កាត់យកដៃឆ្វេងមួយចំហៀងរបស់មេទ័ពប្លន់ទឹកដី បណ្តាលឲ្យវាឈឺចុកចាប់ស្រែករោទិ៍រំពងអាកាស ។ អុងបូក្តៅចិត្តណាស់ ស្ទុះចូលចាក់លោកឧកញ៉ាទាំងទទឹងទិស តែវិរបុរសខ្មែរគេចផុត ហើយវ៉ៃសងមួយដាវខ្វាប់ចំឆ្អឹងជំនីរបស់វា បណ្តាលឲ្យធ្លាយពោះវៀនដួលទធាក់ជើងញ័រទទ្រើកប្រកាច់ស្លាប់យ៉ាងទង្កក់ រកតែស្រែកមួយម៉ាត់ក៏មិនទាន់ផង ។

លោកឧកញ៉ាអោនកាត់ក្បាលអាមេចោរឈ្លានពាន រួចបោះជំហានបំរុងនឹងវិលត្រឡប់ ទៅរកកងទ័ពជាតិវិញ ស្រាប់តែឮសូរសន្ធឹកខ្យល់បក់វូៗមកពីក្រោយ។ គាត់ក្រឡេកទៅឃើញ ទាហានយួនម្នាក់កាន់ដាវសស្វាច ហក់មកពីចម្ងាយផ្ទង់ដាវចាក់តម្រង់គាត់ បំរុងទម្លាយផ្ទាំងទ្រូង ដើម្បីសងសឹកជំនួសគ្នាវា ។ តែលោកឧកញ៉ារហ័សណាស់ គាត់ផ្តួលខ្លួនប្រមៀលពីរបីត្រឡប់ រួចស្ទុះក្រោកឡើងកាប់សងវិញពុំបង្អង់ដៃ បង្ខំឲ្យទាហានយួនចង្រៃត្រូវរបួស ឈាមហូរជោគខ្លួនទន់ជង្គង់ដួលស្លាប់ទាំងបិទភ្នែកមិនជិត ។

លោកហ្មឹនឯកនិងតាម៉ង់ នាំទ័ពវាយប្រហារចោរយួន ស្លាប់នឹងរត់ប្រាសអា-យុអស់ហើយ ក្រឡេករកលោកចៅហ្វាយក្នុងទីសមរភូមិពុំឃើញ គាត់ព្រួយបារម្ភក្នុងចិត្តខ្លាំងណាស់ បញ្ជាទ័ពឲ្យនាំគ្នាស្កាត់រកជាបន្ទាន់ ។ លុះទៅដល់មុខព្រះវិហារ ស្រាប់តែក្រឡេកឃើញ គាត់កំពុងតែយួរក្បាលមេទ័ពអុងបូ ជូតផ្លែដាវដែលប្រ-ឡាក់ឈាម ញាត់ចូលទៅក្នុងស្រោម ហើយងាកមកញញឹមពព្រាយដាក់ពលទាហានទាំងអស់គ្នា ។

ជោគជ័យតាំងនេះបានមកយ៉ាងត្រចះត្រចង់, បង្កើនស្មារតីកងទ័ពខ្មែរស្នេហាជាតិ ឲ្យមានសន្ទុះចិត្តអង់អាចមួយកំរិតទៀត ដើម្បីវាយបណ្តេញក្បាលពួកចោរប្លន់ប្រទេសជាតិមាតុភូមិ ឲ្យចេញផុតពីទឹកដីខ្មែរអព្យាក្រិតនិយមព្រះពុទ្ធសាសនា ។

កងទ័ពជាតិមកជួបជុំគ្នាអស់ហើយ ស្រែកជ័យឃោសមួយឃ្លា បានបន្លឺឡើង

**យ៉ាងកងរំពង ៖**

- ជយោ ! លោកចៅហ្វាយគុយ វីរបុរសខ្មែរកម្ពុជាក្រោម ដ៏ក្លាហាន !
- ជយោ ! លោកចៅហ្វាយគុយ វីរបុរសខ្មែរកម្ពុជាក្រោម ដ៏ក្លាហាន !
- ជយោ ! លោកចៅហ្វាយគុយ វីរបុរសខ្មែរកម្ពុជាក្រោម ដ៏ក្លាហាន !

⌘ ⌘

⌘

-៥-

# អន្ទាក់មេទ័ពយួន អុង-ឡូវ

ក្រោយពីកាត់ក្បាលមេទ័ពយួនអុងបូបានហើយ, ចៅហ្វាយគុយក៏ចាត់ចែងបោះជំរំទ័ព នៅក្នុងវត្តផ្នូរដូងបន្តទៅទៀត ។ លោកខំអប់រំពលទាហាននៅខាងក្នុង និងពលទាហានដែលតាំងនៅគ្រប់ភូមិស្រុក ឲ្យស្គាល់ច្បាស់ពីប្រវត្តិពូជខ្មែរអ្នកជាដើម្បីរួបរួមកម្លាំងគ្នាចេញកំចាត់ចោរយួន ចេញពីទីរួមខេត្តព្រះត្រពាំង ។

លោកបានពន្យល់ប្រាប់បងប្អូនខ្មែរ ពីសាវតាដ៏ថោកទាបរបស់ជនជាតិយួន ដែលមានចិត្តជាចោរ ដើរប្លន់ទឹកដីគេគ្រប់ទីកន្លែង តួយ៉ាងដូចជាប្រទេសចម្ប៉ានិងប្រទេសខ្មែរយើងជាដើម ។

បន្ទាប់ពីបានដើរអប់រំប្រជាពលរដ្ឋស្រុកស្រែចំការហើយ លោកចៅហ្វាយគុយ រៀបចំកងទ័ពដាក់បន្ថែមគ្រប់ទីកន្លែងទៀត ។ ព្រោះលោកយល់ច្បាស់ថា ៖ ការទទួលបរាជ័យនិងបាត់បង់មេទ័ពយួនដ៏ជំនាញក្នុងពេលនេះ ប្រាកដជាធ្វើឲ្យអុងឡូវក្តៅក្រហាយហក់មកទាំងភ្លែនពុំខាន ។

លោកចាត់អ្នកជំនាញការជាច្រើន ឲ្យរចនាគ្រឿងអាវុធ ដាវ លំពែង និងបិតព្រួញបន្ថែមទៀត ដើម្បីកុំឲ្យខ្វះខាតក្នុងសង្គ្រាមវាយលុក ដណ្តើមយកទីរួមខេត្តព្រះត្រពាំងនាពេលខាងមុខនេះ ។

លោកមេបញ្ជាការឈ្មោះ មនោរស់ នៅគ្រប់គ្រងកងទ័ពតាមជាយដែន ។ លោកទេសាសោម ឲ្យកាន់ទ័ពនៅក្នុងស្រុកប្រជុំពល (ស្រុកនេះអ្នកកម្ពុជាក្រោមនាំគ្នាហៅរត់មាត់ថា ស្រុកបន្ទាយក្រ ។ តែចូលមកក្នុងសម័យប្រធានាធិបតីង៉ោ-ឌិនយៀម គេផ្លាស់ឈ្មោះស្រុកនេះ ទៅជាយួនអស់ហើយ) ។

ចំណែកហ្មឹនឯកនិងតាម៉ង់ លោកចៅហ្វាយគុយ ឲ្យកាន់ជាមេទ័ពស្រួចនៅកណ្តាល សំរាប់ការពារផ្ទៃក្នុងនិងបញ្ជាការទូទៅ ។

ក្រោយពេលដែលលោកចៅហ្វាយសឺន-គុយ វាយដណ្តើមយកវត្តផ្នូរដូងបានមកវិញ យួនតែងចាត់ពួកវាឲ្យដើរ បញ្ចុះបញ្ចូលបងប្អូនខ្មែរ តាមរបៀបចិត្តសា-ស្ត្រ, ហើយក្រុមមួយទៀត វាឲ្យដើរពន្យល់ប្រាប់រាស្ត្រខ្មែរយើង ឲ្យស្អប់លោកចៅហ្វាយគុយ ។ ពួកយួនពន្យល់ថា ចៅហ្វាយគុយ ជាជនចោលម្សៀតក្បត់ជាតិមាតុភូមិ បង្កើតជាបក្សពួកដើរប្លន់គ្រប់កន្លែង កាប់សម្លាប់តែបងប្អូនខ្មែរគ្នាឯង ។ ពេ-លនេះពួកវាបានមកជួយបងប្អូនខ្មែរ ឲ្យរួចពីព្រោះថ្នាក់ចោរប្លន់ហើយ ។

រាល់ថ្ងៃ ការប្រយុទ្ធគ្នារវាងយួននិងខ្មែរ លស់ពេលតិចណាស់ ដែលមុខងារគ្មានប្រឡាក់ឈាម ។ ថ្ងៃវាឲ្យទាហានវាដើរឃោសនាតាមភូមិខ្មែរ ដល់យប់វាក្លែងខ្លួនជាចោរលួចប្លន់ទ្រព្យសម្បត្តិ កាប់សម្លាប់ខ្មែរ ចាប់កូនក្រមុំខ្មែរយកទៅធ្វើបាបហើយសម្លាប់ចោលតាមអំពើចិត្ត ។ រួចវាឲ្យពួកវាដើរឃោសនាបន្តទៅទៀតថា ការប្លន់សម្លាប់បងប្អូនខ្មែរនេះ គឺជាពួកចៅហ្វាយគុយទាំងអស់ សូមបងប្អូនប្រុងប្រយ័ត្នឲ្យមែនទែន ថ្ងៃណាមួយវានាំគ្នាដុតបំផ្លាញផ្ទះសំបែងបងប្អូនហើយ ។

នេះជារឿងហូរទឹកភ្នែកមួយ ដែលបងប្អូនខ្មែរកម្ពុជាក្រោម សព្វថ្ងៃបៀមខ្លះឈាមរាប់សតវត្សមកហើយ ដោយសារតែអំពើបង្វេងដានរបស់យួនចង្រៃនេះ ។ ដូច្នេះហើយ បានជាបងប្អូនខ្មែរនៅកម្ពុជាក្រោម កាន់ទម្លាប់មួយគឺ មិនឲ្យស្ត្រីខ្មែរយកប្ដីយួនទាល់តែសោះ ទោះបីមានភ្លាត់មួយៗ ក៏អ្នកនោះច្រើនឈ្លក់វង្វេងដោយការបង្វិលរបស់ពួកវាតែប៉ុណ្ណោះ (ហើយត្រូវសង្គមខ្មែរកាត់ផ្ដាច់ផងដែរ) ។

និយាយពីទ័ពខ្មែរយើងនៅវត្តផ្លូវដូងម្ដងទៀត ។ កាលបើបានគ្នាចុះចូលរួមមកម្លាំងច្រើនហើយ មានមេកោយខ្លះរកាំរកូសជាមួយគ្នា រហូតដល់ទៅមើលមុខគ្នាលែងត្រង់តែម្ដង ។ ខ្លះសង្គ្រឹតធ្មេញដាក់គ្នា ចង់ស៊ីសាច់ទាំងរស់ ព្រោះតែនិយមការច្រណែនឈ្នានិសគ្នា ។

លោកតាម៉ង់ ដៃគូលោកហ៊្មឹនឯក ដែលមានចិត្តស្មោះត្រង់ចំពោះជាតិត្រូវស្លាប់យ៉ាងអាថ៌កំបាំង ។ ស្លាប់ដោយមានគ្នាឯងលួចសម្លាប់ តែមិនដឹងជាមកពីរឿងហេតុអ្វី ?

លោកចៅហ្វាយគុយ ឲ្យគេស៊ើបអង្កេតរកមុខអ្នកសម្លាប់តាម៉ង់ ក៏រកមិនឃើញទាល់តែសោះ ។ លោកមានការសោកស្ដាយ និងអន្ទះអន្ទែងក្នុងចិត្តយ៉ាងខ្លាំងចំពោះការបាត់បង់មេបញ្ជាការដ៏ស្មោះត្រង់ម្នាក់នេះ ។ តាមឯកសារបញ្ជាក់ថា លោកតាម៉ង់ស្លាប់នៅពេលថ្ងៃត្រង់ ខាងកើតវត្តផ្លូវដូង (ស្រុកកញ្ចោងផ្សា) ។

ពេលដែលលោកចៅហ្វាយគុយប្រជុំមេបញ្ជាការគ្រប់គ្នា ស្រាប់តែបាត់តាម៉ង់ម្នាក់ឯង មិនឃើញមកប្រជុំសោះ ។ លោកចៅហ្វាយក៏ចាត់ឲ្យដើររកគ្រប់ច្រកល្ហកអស់កន្លះថ្ងៃ ស្រាប់តែឃើញសពលោកតាម៉ង់ ដេកស្ដូក ខ្លួនជាំខ្មៅ នៅក្រោមដើមស្លែង ចម្ងាយប្រហែល៣០០ម៉ែត្រពីជុំវិញវត្តផ្លូវដូង ។

ការសម្លាប់បិទមុខនេះ រកកត់សម្គាល់មិនបានទេ ។ ភូឈ្មួយគង់និងតាម៉ង់ធ្លាប់ទាស់ទែងគ្នាពីដើមមកមែន។ ពេលនេះបើថាភូឈ្មួយគង់ល្បងយកទៅសម្លាប់ក៏ថាមិនត្រូវដែរ, ព្រោះថ្ងៃនេះភូឈ្មួយគង់អត់មានចេញដើរទៅណាឆ្ងាយ ដូចជាថ្ងៃមុនឡើយ ។ បើចេញដើរទៅណាឆ្ងាយ ក៏មិនកំបាំងពីភ្នែកលោកហ៊្មឹនឯក ដែលជាអ្នកឃ្លាំមើលការក្បត់របស់វាដែរ ។

ពេលមុនៗ ភូឈ្មួយគង់បាត់មែន តែគេបានសុំច្បាប់លោកចៅហ្វាយដើរអប់រំអ្នកស្រុក និងបំពេញបេសកកម្មផ្សេងៗ ។ តាម៉ង់ស្លាប់នេះ ធ្វើឲ្យពលទាហានទាំងអស់ខ្លោចផ្សាគ្រប់គ្នា ព្រោះមនុស្សល្អពុំគួររស់មិនបានយូរដូច្នេះសោះ ។

ចំណែកលោកហ្មឺនឯកវិញ កាលបើតាម៉ង់ ចិត្តមួយថ្លើមមួយស្លាប់ដូចខ្មោចតែហោងយ៉ាងនេះ លោកសំរេចចិត្តថា ត្រូវតែសម្លាប់ភូឈ្មួយគង់សងសឹកជំនួសតាម៉ង់ឲ្យបាន ។ លោកហ្មឺនឯកនឹកឃើញសំដីតាម៉ង់និយាយថា «បើខ្ញុំមិនស្លាប់ដោយសង្គ្រាមទេ គឺប្រាកដជាស្លាប់ដោយឧបាយកលរបស់ភូឈ្មួយគង់មិនខាន»

សំដីនេះ បើហ្មឺនឯកនាំយកទៅជំរាបលោកឧកញ៉ាទៅ ក៏គ្មានភស្តុតាងជាក់ស្តែង អាចឲ្យលោកជឿបានដែរ ។ ម្យ៉ាងទៀតនាំឲ្យលោកចោទថា គាត់ជាមេក្លោងនាំបំបែកបំបាក់សាមគ្គីផ្ទៃក្នុងទៀតផង ។ សមបើភូឈ្មួយគង់ជាជំនិតរបស់លោកឧកញ៉ាស្រាប់ វាអាចនិយាយបញ្ចេញបញ្ចូលស្រេចតែក្បាលចិត្តទៀតផង ។

មូលហេតុទាំងនេះហើយ ដូចមានទ្រឹស្តីអន្តរជាតិមួយពោលថា «ភាសារបស់ចីបក ពិរោះហើយឆ្ងាញ់ ច្រើនតែរស់នៅក្បែរបល្ល័ង្ក» ។

ការគិតច្រើនប្រការនេះ ហ្មឺនឯកចង់វិលវល់អស់មិនដឹងជាសំរេចចិត្តដើរផ្លូវណាមួយឲ្យស្រួលទេ ។ បើមិនប្រាប់ទៅ ការឈឺចាប់ក្នុងផ្លូវចិត្ត ប្រាកដជាគ្មានថ្ងៃចប់ឡើយ ។ បើគេចខ្លួនចេញពីទីនេះ ហើយសុខចិត្តដើរច្បាំងជាមួយយួនម្នាក់ឯងស្លាប់រស់ប្រសើរជាងការរស់នៅក្នុងសង្គមខ្វះយុត្តិធម៌ដែរ ។

លោកហ្មឺនឯករត់ចេញពេលនេះ មានការសោកស្តាយលោកឧកញ៉ាខ្លាំងណាស់ ព្រោះគាត់ជាវិរបុរសខ្មែរដ៏ជាគំរូ មានចិត្តស្មោះត្រង់ចំពោះជាតិយ៉ាងពិតប្រាកដ

លោកហ្មឺនឯកដើរចេញពីទីនោះ ពុំមានឲ្យនរណាដឹងម្នាក់ឡើយ ។ ឯកសារបានបញ្ជាក់ថា លោកហ្មឺនឯករត់ទៅបង្កទ័ពនៅស្រុកបាសាក់ ហើយបន្តការកាប់សម្លាប់ពួកយួនយ៉ាងអង់អាច ។

នៅក្នុងកងទ័ពខ្មែរ មានកើតចលាចលយ៉ាងខ្លាំង ដោយបាត់បង់មេទ័ពខ្លាំងពូកែពីរនាក់ យ៉ាងអាថ៌កំបាំងបន្តបន្ទាប់គ្នា ។ លោកចៅហ្វាយគុយ ពីដើមមានសហការីជំនិត៥រូបពិភាក្សាគ្នា ឥឡូវបាត់អស់ពីរហើយ ធ្វើឲ្យលោកតែលតោលក្នុងចិត្តរកច្រកដោះស្រាយពុំរួចសោះ ។ សង្ឃឹមលើភូឈ្មួយគង់ គ្រាន់តែបានជាទីប្រឹក្សាឆ្វេងស្តាំប៉ុណ្ណោះ ។ សង្ឃឹមឲ្យជួយពេញដៃ ដោយបញ្ជាទ័ពចេញទៅច្បាំងនឹងយួនញញើតញញើមបានតែមាត់ក្រៅ រកមិនបានដូចហ្មឺនឯកនិងតាម៉ង់នោះឡើយ ។ លោកចៅហ្វាយគុយបានចាត់ការ ឲ្យគេដើរស៊ើបរកលោកហ្មឺនឯក ឲ្យមកកាន់កងទ័ពវិញ តែរកមិនឃើញសោះ ។ ឃើញតែអក្សរដែលគាត់បានសរសេរដាក់លើក្តារមួយសន្លឹកពីរបីម៉ាត់ថា «ខ្ញុំហ្មឺនឯក សុំទៅច្បាំងយួនម្នាក់ឯងហើយ»

កន្លងទៅប្រហែលមួយអាទិត្យ ទ័ពយួនអុងឡូវ ឮដំណឹងថា មេទ័ពខ្មែរម្នាក់ស្លាប់ ម្នាក់បាត់ខ្លួន ពួកវាបានដែកីលើកទ័ពមកឡោមព័ទ្ធទីតាំងទ័ពលោកទេសាសោម ដែលនៅប្រចាំការស្រុកប្រជុំពល យ៉ាងគគ្រឹកគគ្រេង ។ តែទ័ពលោកអន្ទ្យាសោមបានដឹងមុន ក៏ត្រៀមខ្លួនចាំប្រយុទ្ធទាំងយប់ទាំងថ្ងៃពេលនោះ... ទ័ពខ្មែរមានកម្លាំងស្តួចស្តើងពេក ទប់ជាមួយពួកយួនមិនបាន ក៏បាក់ទ័ពអស់រលីង ហើយលោកអន្ទ្យាសោម ត្រូវពួកវាចាប់បាន បំរុងយកទៅប្រហារជីវិតចោល តែមេវាម្នាក់ឃាត់ទាន់ ឲ្យនាំយកទាំងរស់ទៅប្រគល់ឲ្យអុងឡូវសំរេចសេចក្តីសិន ។

ភ្លាមនោះ ទឹកមុខអន្ទ្យាសោមនៅស្រស់ដដែល ។ មេទ័ពយួនបានប្រើឧបាយកលល្បួងលួងលោមអន្ទ្យាសោម ឲ្យរួមកម្លាំងជាមួយវា ។ វាប្រើការស្និទ្ធស្នាលជាមួយលោកមេទ័ពខ្មែរ បីដូចមនុស្សធ្លាប់ស្គាល់គ្នារាប់សិបឆ្នាំមកហើយ ។ តែលោកអន្ទ្យាសោម មិនចេញស្តីមួយម៉ាត់ទាល់តែសោះ សុខចិត្តបណ្តោយខ្លួនឲ្យពួកវាធ្វើទារុណកម្មតាមអំពើចិត្ត ។

ដល់វាសួរការណ៍សម្ងាត់មិនប្រាប់ ម្នាក់ៗធ្វើបាបលោកអន្ទ្យាសោមបែកញើសជោកខ្លួន ។ ពួកវាទាល់ចំណេះ ក៏នាំមេទ័ពទៅប្រាប់អុងឡូវ ឲ្យជំរះរឿងនេះផ្ទាល់ខ្លួនតែម្តង ។ អុងឡូវឲ្យគេនាំលោកអន្ទ្យាសោមមកដល់ហើយសួរមួយឃ្លាថា ៖

- ឯងប្រាប់អញតាមត្រង់មក អញនឹងឲ្យឯងរួចខ្លួន ទៅជួបជុំប្រពន្ធកូនវិញភ្លាម ។ ឯងដឹងស្រាប់ហើយ ជនជាតិយួនមិនដែលសម្លាប់អ្នកណា ដែលមានចិត្តស្មោះត្រង់នឹងជនជាតិខ្មែរនោះទេ ។ គោលបំណងធំបំផុតរបស់យើងគឺ ចង់សម្លាប់តែចៅហ្វាយគុយម្នាក់ប៉ុណ្ណោះ ។ ក្រៅពីនោះយើងឲ្យរួចខ្លួនទាំងអស់ ។ ចៅហ្វាយគុយវាជាមេបំបះបំបោរប្រជារាស្ត្រ ប្រឆាំងនឹងនយោបាយព្រះចៅក្រុងវេរបស់យើង ។ ឥឡូវនេះ តើចៅហ្វាយគុយរៀបចំគំរោងការណ៍ដូចម្តេចខ្លះ ? ប្រាប់យើងមក យើងឲ្យឯងរួចខ្លួនភ្លាម ។

ទោះបីមេទ័ពយួនអុងឡូវ ខំលួងលោមបញ្ជាក់សួរលោកទេសាសោម បែកពពុះមាត់ដូចឆ្កែឆ្កួត ក៏មេទ័ពខ្មែរនៅតែអង្គុយធ្វើព្រងើយ ព្រមទាំងបញ្ចេញបុកពាយ៉ាងអង់អាចមួយកំរិតទៀត បណ្តាលឲ្យវាក្តៅក្រហាយស្ទើរស្រក់ឈាមពីភ្នែក ។ រំពេចនោះនេចោរហន្សំ បញ្ជាឲ្យទាហានវាចាប់លោកទេសាសោមចងស្លាបសេកបណ្តើរយកទៅក្រោមដើមជ្រៃក្រឹមមួយ ដែលមានម្លប់យ៉ាងត្រជាក់ ស្ថិតនៅជាប់នឹងរបងវត្តគរគី ក្នុងទីរួមខេត្តព្រះត្រពាំង ។

មុននឹងស្លាប់ មេទ័ពខ្មែរដ៏ក្លាហាន បានពោលពាក្យប្រមាថចោរយួនឥតតក់ស្លុត ៖

- ទោះបីខ្លួនអញរលាយទៅជាផេះ ក៏ពួកឯងមិនអាចរកឯកសារសម្ងាត់ និង

ចាប់ខ្លួនលោកចៅហ្វាយគុយ ព្រមទាំងហ៊្មឹនឯកបានដែរ ។ ពិតមែនតែឯងបានប្រើឧបាយកលយ៉ាងខ្មៅងងឹត ដោយទិញក្បាលភូឈ្មួយគង់ឲ្យរួមគំនិតសម្លាប់តាម៉ង់នោះ តែឯងកុំភ្លេចថា បើព្រះអាទិត្យ ព្រះច័ន្ទនៅតែរះ កូនខ្មែរទាំងអស់ប្រាកដជាភ្ញាក់ស្មារតី នៅថ្ងៃណាមួយ រួបរួមកម្លាំងគ្នាវាយសំពងក្បាលពួកឯង រហូតស្លាប់រកដីកប់គ្មានជាប្រាកដ ។

មេទ័ពអុងឡូវ ឮសំដីវាយបន្ទោករបស់ទេសាសោម ក៏ក្តៅគុម្ពត្រចៀក មុខក្រហមដូចមាន់គក ស្រែកបញ្ជាឲ្យបរិវារ កាប់ប្រហារមេទ័ពខ្មែរជាបន្ទាន់ ។ ប៉ុន្តែគួរឲ្យអស្ចារ្យណាស់ ព្រោះទាហានយួនកាប់ចិញ្ច្រាំសាច់លោកទេសាសោម បាក់ដាវអស់រាប់ផ្លូនទៅហើយ ពុំមានរលាត់ស្បែកសូម្បីប៉ិនសរសៃសក់ឡើយ ។

ចោរយួនទាល់ច្រក ក៏សំរួចឈើស្រួចលលែម ហើយបុកបញ្ចូលតាមទ្វារធំបញ្ជោស់ឡើងលើ ទើបធ្វើឲ្យទេសាសោមផុតជីវិតលាចាកលោកនេះទៅ ទុកនៅតែសំណើចក្អាកក្អាយរបស់ពួកចោរឈ្លានពានតែប៉ុណ្ណោះ ។

ពួកវាសម្លាប់លោកទេសាសោមរួច ក៏បញ្ជូនទាហានខ្មែរម្នាក់ទៀតពីទីឃុំឃាំង មកគំរាមកំហែងសួរចម្លើយ ។

- ហ៊្មឹនឯករត់ទៅឯណា ?... ប្រាប់យើងឲ្យត្រង់មក យើងនឹងទុកជីវិតឲ្យឯងរស់ បានត្រឡប់ទៅជួបជុំប្រពន្ធកូនក្នុងថ្ងៃនេះវិញ ។

ទាហានខ្មែរដែលមានស្មារតីទន់ខ្សោយ នឹកស្មានថាយួនឲ្យរួចខ្លួនមែន ក៏និ-យាយប្រាប់ទាំងញ័រខ្លួនទទ្រើក ៖

- បាទ ! សព្វថ្ងៃនេះលោកហ៊្មឹនឯក បានរត់ទៅបង្កទ័ពក្នុងស្រុកបាសាក់ឯ-ណោះ ។ គាត់ជាមេទ័ពខ្មែរដ៏ពូកែល្បីល្បាញ នៅភូមិភាគដែនដីកម្ពុជាក្រោមនេះ។ អស់លោកប្រហែលជា ចាប់គាត់ពុំងាយបានទេ !...

មេទ័ពអុងឡូវបញ្ជាក់សួរដឹងហេតុការណ៍សព្វគ្រប់ហើយ ក៏ផ្ទុះសំណើចកងរំពង រួចបញ្ជាគ្នាវាឲ្យចាប់យកទាហានខ្មែររូបនោះ ទៅសម្លាប់ចោលភ្លាមៗ ។ នេះហើយជាគំនិតបោកប្រាស់យ៉ាងច្រាសជើង របស់ចោរយួនដែលជាសត្រូវប្រចាំប្រវត្តិសាស្ត្ររបស់ជាតិខ្មែរ ។

⌘ ⌘

⌘

# -៦-

# ឧត្តមគតិលោកចៅហ្វាយគុយ

លោកតាម៉ង់ស្លាប់ដោយអាចម៍កាំបាំង, ហ៊្មឹនឯកភៀសខ្លួនរស់ចេញពីកងទ័ព, ទេសាសោមត្រូវស្លាប់ក្នុងក្រញាំចោរយួនអុងឡូវ ។

ព្រឹត្តិការណ៍ទាំងនេះធ្វើឲ្យភូឈ្មួយគង់ញញឹមបិទមាត់មិនជិត ព្រោះគោលដៅក្បត់ជាតិរបស់គាត់ជិតបានសំរេចជោគជ័យហើយ ។ ឥឡូវនេះជនអសិរពិសកំពុងតែរាវរកមធ្យោបាយ ដើម្បីសម្លាប់លោកចៅហ្វាយគុយ ដែលជាអ្នកមានគុណធ្លាប់ចិញ្ចឹមក្បាល និងលើកដម្កើងបុណ្យស័ក្តិវាឲ្យមានឋានៈដល់កំពូលទៀតផង ។

លោកចៅហ្វាយគុយពុំដឹងថាភូឈ្មួយគង់ ជាជនក្រពើវង្វេងបឹង បង្កប់គំនិតខ្មៅងងឹត ក្នុងគោលបំណងសម្លាប់លោកសងគុណទេ ។ ពិតមែនតែលោកបានបាត់បង់សហការីដ៏ជំនាញបីរូប ដែលសកម្មភាពវាយកំចាត់ចោរយួនរបស់លោកនៅតែមានចលនារស់រវើកជានិច្ច ។ លោកបានសំរេចក្នុងចិត្តជាស្រេចថា «ករណីរបស់លោកគឺ គឺដេញកំចាត់ខ្មាំង ឲ្យអស់ពីប្រទេសជាតិ ទោះបីស្លាប់រស់ក៏មិនរាថយជាដាច់ខាត» ។

ពេលនោះ នៅក្នុងទីរួមខេត្តព្រះត្រពាំង យួនអុងឡូវបានចេញប្រកាសបិទគ្រប់ទិសទីថា «បើអ្នកណាចាប់ចៅហ្វាយគុយបាន វានឹងឲ្យរង្វាន់តាមសេចក្តីត្រូវការហើយលើកតាំងឲ្យធ្វើជាម្ចាស់ស្រុកទៀតផង»...

យួនបានប្តូរផ្លាស់មធ្យោបាយ ពីសំណាក់មួយទៅសំណាក់មួយ ដើម្បីធ្វើសង្គ្រាមចិត្តសាស្ត្រជាមួយចៅហ្វាយគុយ ។ ព្រោះវាយល់ថា អតីតប្រមុខខេត្តព្រះត្រពាំង ស្រឡាញ់ប្រជារាស្ត្រណាស់ គាត់ពិតជាហ៊ានបូជាជីវិតគ្រប់បែបយ៉ាង ដើម្បីរាស្ត្ររស់ពុំខាន ។ ដូច្នេះវាចេញប្រកាសរួច ក៏តាំងបញ្ជាពលទាហានឲ្យឈប់ចេញច្បាំងហើយដើរកាប់សម្លាប់ធ្វើបាបរាស្ត្រខ្មែរយ៉ាងឃោរឃៅព្រៃផ្សៃ ។ វាបានប្រ-កាសទៀតថា សកម្មភាពដ៏សាហាវដែលពួកវាលើកយកមកអនុវត្តពេលនេះ បញ្ចប់ទៅបាន លុះត្រាតែចៅហ្វាយគុយហ៊ានយកជីវិតមកប្តូរស្លាប់ ។

ដោយអត់ទ្រាំនឹងការឈឺចាប់ យ៉ាងខ្លោចផ្សារបស់ប្រជាជនខ្មែរស្លូតត្រង់ពុំបាន លោកចៅហ្វាយគុយ ក៏សុខចិត្តធ្វើពលិកម្មគ្រប់បែបយ៉ាង ដោយចូលខ្លួនឲ្យសត្រូវយួនចាប់ទាំងរស់តែម្តង ។

មេទ័ពអុងឡូវ កាលបើឃើញលោកចៅហ្វាយគុយ ព្រមទម្លាក់កន្ទុយចុះញ៉ម

ហើយ ក៏ស្ទុះមកទទួលយ៉ាងរាក់ទាក់ ព្រមទាំងហាមឃាត់ពលទាហាន មិនឲ្យប៉ះពាក់ខ្លួនគាត់យ៉ាងដាច់ខាត ។

មេទ័ពឃួនអញ្ជើញលោកចៅហ្វាយគុយ ចូលទៅដល់ក្នុងជំរំហើយ ក៏ពោលពាក្យដោយបញ្ចេញទ្រឹស្តីយ៉ាងទន់ភ្លន់ថា ៖

- មនុស្សយើង បើគិតឲ្យសព្វគ្រប់ទៅ មិនគួរទាស់ទែងខ្វែងគំនិតកាប់សម្លាប់បង្ហូរឈាមគ្នាសោះ ។ ខ្ញុំមកនេះ ក៏ព្រោះតែទទួលបញ្ជាពីព្រះចៅក្រុងវ៉េ ឲ្យមកចងមិត្តភាពជាមួយនឹងលោកដែរ ។ បើបានលោកយល់ព្រមយ៉ាងនេះ ខ្ញុំសន្យាថា មិនបោះបង់មនុស្សមានចិត្តស្មោះត្រង់ ដូចលោកចោលយ៉ាងដាច់ខាត ។

លោកចៅហ្វាយគុយរក្សាទឹកមុខធម្មតា ហើយឆ្លើយតបទៅឆ្កែបំរើព្រះចៅក្រុងវ៉េវិញថា ៖

- លោកមានប្រសាសន៍នេះពិតជាត្រូវមែន ! នៅក្រោមមេឃលើដីនេះ គ្មានអ្នកណាម្នាក់ចង់កាន់អាវុធបង្ហូរឈាមគ្នានោះទេ ។ ប៉ុន្តែពេលវេលាតម្រូវឲ្យហើយ ទោះបីគេចក៏មិនផុតដែរ ។ ខ្ញុំចូលខ្លួនមកនេះ ដើម្បីប្រគល់ជូនលោកសំរេចតាមសេចក្តីត្រូវការ តែសុំឲ្យលោកឈប់ប្រព្រឹត្តអំពើព្រៃផ្សៃទៅលើប្រជារាស្ត្រស្លូតត្រង់របស់ខ្ញុំ ចាប់តាំងពីថ្ងៃនេះតទៅ ។

មេទ័ពអុងឡូវឮសំណូមពររបស់លោកចៅហ្វាយគុយ ក៏ញញឹមងក់ក្បាលយល់ព្រម ហើយបន្លឺពាក្យថា ៖

- សេចក្តីត្រូវការរបស់លោកក្នុងពេលនេះ ស្រួលនឹងបញ្ចប់ណាស់ គឺស្ថិតនៅលើលោកនិងខ្ញុំពិគ្រោះគ្នាតែពីរនាក់ប៉ុណ្ណោះ ។ បំណងរបស់ខ្ញុំចង់តែងតាំងលោកឲ្យធ្វើជាតំណាងប្រជារាស្ត្រខ្មែរទាំងអស់លើដែនដីកម្ពុជាក្រោមនេះ ព្រោះលោកជាមនុស្សម្នាក់ ដែលមានប្រជាប្រិយភាពពុំអាចរកបានឡើយ ។

លោកចៅហ្វាយគុយគ្រវីក្បាលឆ្លើយបដិសេធយ៉ាងបន្ទាន់ ៖

- ខ្ញុំសុំមិនទទួលដំណែងអ្វីទាំងអស់ ! សូមលោកប្រគល់តំណែងនេះទៅឲ្យសហការីខ្លះ ដែលលោកបានគ្រោងទុកមកជាយូហើយនោះចុះ !

- លោកបដិសេធអីចឹងមិនបានទេ ! ព្រោះនេះជាបញ្ជាដាច់ណាត់របស់ព្រះចៅក្រុងវ៉េណា ។ ចំណែកភូឈួយគង់ ដែលលោកចង់និយាយអម្បាញ់មិញនេះ គឺខ្ញុំមានមុខការម៉្យាង ឲ្យគេធ្វើរួចទៅហើយ ។

ពេលនេះលោកចៅហ្វាយគុយ រឹតតែយល់ច្បាស់ពីក្រយៅក្បត់ជាតិរបស់ភូ-ឈួយគង់ ដែលលក់ក្បាលបំរើសត្រូវប្រទេសជាតិ ប្រឌិតឧបាយកលខ្មៅងងឹតសម្លាប់តែគ្នាឯង ឲ្យមានភាពទន់ខ្សោយ រហូតធ្លាក់ដល់កំរិតទាបបំផុតដូចសព្វថ្ងៃនេះ ។

លោកចៅហ្វាយគុយឈឺចាប់ក្នុងខ្លួនខ្លាំងណាស់ ចំពោះជនដែលមានឈាមជ័រជាខ្មែរ ហើយក្បត់ខ្មែរយ៉ាងនេះ ។ ទីបំផុតលោកក៏សំរេចចិត្ត ព្រមរស់នៅជាបណ្តោះអាសន្នក្នុងជំរំទ័ពយួន ដើម្បីរកឱកាសជំរះបញ្ជីជនក្បត់ជាតិ សងបំណុលឈាម និងគំនុំឈឺចាប់របស់តាម៉ង់, ហ៊ឹនឯក, ទេសាសោម ព្រមទាំងប្រជារាស្ត្រខ្មែរទាំងអស់ ដែលបានធ្វើពលិកម្មដោយស្មោះអស់ពីដួងចិត្ត ក្នុងការបំរើប្រទេសជាតិមាតុភូមិ ។

មេទ័ពអុងឡូវ ឃើញលោកចៅហ្វាយគុយ យល់ព្រមទទួលរស់នៅតាមសេចក្តីត្រូវការរបស់គេហើយ គេក៏រំលឹកឡើងរឿងអតីតកាលដ៏ជូរចត់មួយ មកបញ្ជាក់បន្ថែមទៀត ៖

– ជនជាតិខ្ញុំមានសេចក្តីត្រេកអរណាស់ ដែលបានចាប់ដៃរួមលោហិតជាមួយជនជាតិរបស់លោក ។ រឿងនេះមិនខុសពីសម័យមុន ដែលព្រះបាទជ័យជេដ្ឋាទី២ ទទួលព្រះអង្គម្ចាស់ក្សត្រីកូជិនស៊ិន, បុត្រីទី៨របស់ព្រះចៅយ៉ាឡុងយើងធ្វើជាម-ហេសីដែរ ។ កាលនោះគឺ ព្រះអង្គចង់រឹតចំណងមិត្តភាពរវាងប្រទេសយើងទាំងពីរ ដូចលោកអីចឹងដែរណា៎ !...

ភាសានេះ ធ្វើឲ្យលោកចៅហ្វាយគុយក្តៅឆួលចុងច្រមុះស្ទើរទប់កំហឹងពុំបាន ។ តែលោកខំអត់សង្កត់ចិត្តមួយរយៈទៀតសិន ដើម្បីជំរះបញ្ជីជាមួយពួកវា ក្នុងថ្ងៃណាមួយខាងមុខនេះ ។

មិនយូរប៉ុន្មាន ព្រះចៅក្រុងវ៉េក៏អស់រាជ្យ ធ្លាក់ទៅលើដៃស្តេចយួនម្នាក់ទៀតឈ្មោះព្រះចៅមិញម៉ាង ក្នុងឆ្នាំ១៨២១ ។ ស្តេចក្រោយនេះកាចសាហាវណាស់ គ្រាន់តែឡើងគ្រប់គ្រងរាជ្យសម្បត្តិភ្លាម ក៏ចេញបញ្ជាដាច់ណាត់ ប្រាប់បណ្តារាស្ត្រខ្មែររស់នៅលើទឹកដីកម្ពុជាក្រោមទាំងមូល ឲ្យផ្លាស់ប្តូរទំនៀមទំលាប់ និងច្បាប់ព្រះពុទ្ធសាសនាខ្មែរ ហើយគោរពដើរតាមប្រពៃណីនិងទំនៀមទំលាប់របស់ជនជាតិយួនទាំងអស់ ។

សេចក្តីប្រកាសរបស់ព្រះចៅយួនមានដូចតទៅ ៖

លោកសង្ឃគ្រប់វត្ត និងប្រជារាស្ត្រខ្មែរទាំងអស់ ដែលរស់នៅលើកូសាំងស៊ីន ត្រូវតែគោរពតាមច្បាប់បញ្ញត្តិរបស់យើងជាដាច់ខាត ។

១– លោកសង្ឃខ្មែរ ត្រូវស្លៀកពាក់តាមរបៀបលោកសង្ឃយួន ត្រូវកោរសក់ទុកចិញ្ចើម ហើយឆាន់បាយពេលល្ងាច ដូចជារាស្ត្រធម្មតា ។ ត្រូវស្លៀកខោជើងពីរ ពាក់អាវផាយយកត្រង់ពណ៌ឈាមជ្រូក ។ ពេលសូត្រធម៌ម្តងត្រូវវាយត្រដោកផង ។

២– រាស្ត្រខ្មែរទាំងស្រីប្រុស ត្រូវទុកសក់ឲ្យវែងដល់ចង្កេះ ហើយបួងធ្វើជាកំ

ប៉ោយឲ្យបានគ្រប់ៗគ្នាទាំងអស់ ។

បើលោកសង្ឃ ឬខ្មែរណាម្នាក់មិនស្តាប់តាមបញ្ជាយើងជាព្រះចៅយួន នឹងត្រូវប្រហារជីវិតអស់មួយពូជជាកំហិត ។

សេចក្តីប្រកាសយ៉ាងច្រាសជើងរបស់ព្រះចៅមិញម៉ាង ធ្វើឲ្យប្រជារាស្ត្រខ្មែរទាំងអស់ ដែលរស់នៅលើដែនដីកម្ពុជាក្រោម ក្តៅក្រហាយយ៉ាងខ្លាំង នាំគ្នាក្រោកឈរឡើង ធ្វើបាតុកម្មទាមទារសិទ្ធិសេរីភាពគ្រប់ទីកន្លែង ។

ព្រះសង្ឃខ្មែរទាំង៥០៧វត្ត បានធ្វើសេចក្តីរាយការណ៍ ផ្ញើទៅជូនលោកចៅ-ហ្វាយគុយ ដើម្បីប្រឆាំងតវ៉ានឹងអំណាចផ្តាច់ការរបស់ស្តេចយួនលើព្រះពុទ្ធសា-សនាខ្មែរ ។

រឿងនេះ លោកចៅហ្វាយគុយបានចេញមុខ ធ្វើការតវ៉ាជាមួយមេទ័ពយួនអុងឡូវ សុំមិនឲ្យផ្លាស់ប្តូររបបគ្រប់គ្រងរបស់ប្រជាជាតិខ្មែរ ជាច្រើនលើកច្រើនគ្រាណាស់មកហើយ តែពុំបានសំរេចតាមបំណងសោះ ។

ឥឡូវនេះ លោកចៅហ្វាយគុយប្តេជ្ញាចិត្តចូលទៅជួបលោកមេទ័ពអុងឡូវ ជាចុងក្រោយបង្អស់ម្តងទៀត ទោះបីត្រូវចាប់អង្កន់សាច់ទាំងរស់ក៏មិនរាថយដែរ ។

គ្រាន់តែឃើញលោកចៅហ្វាយគុយចូលទៅដល់ក្នុងជំរំភ្លាម មេទ័ពយួនអុងឡូវក៏ជំឡើងធ្មេញយ៉ាងសាហាវ សម្លក់អ្នកតំណាងប្រជារាស្ត្រខ្មែរដោយអាការៈធុញទ្រាន់ជាទីបំផុត ។

អាកប្បកិរិយានេះធ្វើឲ្យលោកចៅហ្វាយគុយ នឹកខ្ញាញ់ក្នុងចិត្តជាខ្លាំង ប៉ុន្តែកាលៈទេសៈតម្រូវហើយ គាត់ក៏ខាំមាត់សង្កត់ចិត្ត ឱនមុខទទួលការអាម៉ាស់ ពោលពាក្យអង្វរវាដោយទន់ភ្លន់ ៖

- លោកមេទ័ពជាទីគោរព ! ក្នុងនាមខ្ញុំជាអ្នកតំណាងឲ្យបងប្អូនខ្មែរ និងព្រះសង្ឃទាំងអស់នៅលើដែនដីកម្ពុជាក្រោមនេះ ខ្ញុំសូមលោកមេត្តាអនុញ្ញាតធ្វើសេចក្តីរាយការណ៍ ផ្ញើទៅថ្វាយព្រះចៅមិញម៉ាងវិញថា ប្រជារាស្ត្រខ្មែរនិងព្រះសង្ឃទាំងអស់ ពុំអាចអនុវត្តតាមបទបញ្ជាព្រះចៅបានឡើយ ។

មេទ័ពអុងឡូវស្តាប់ឮភ្លាមក៏ទះតុផាំង ស្ទុះក្រោកឡើងគ្រហឹមងឺលដូចខ្លាត្រូវរបួស ។ មួយសន្ទុះទើបស្រែកសន្ធប់ស្មារតីលោកអតីតប្រមុខខេត្តព្រះត្រពាំង ៖

- ហ៊ឺះ ! ខ្ញុំធុញទ្រាន់ណាស់, លោកនិយាយតែរឿងដដែលៗហ្នឹងរាប់រយដងទៅហើយ មិនចេះចប់សោះ ។ ឬមួយក៏លោកមិនចេះស្តាប់ភាសាខ្មែរទេ ខ្ញុំបានប្រាប់ហើយថា គ្មានអ្នកណាអាចជំទាស់នឹងបទបញ្ជាព្រះចៅក្រុងវេបានទេ ។ ម៉្យាងទៀតគ្រាន់តែមានការផ្លាស់ប្តូរទំនៀមទំលាប់ និងរបៀបគ្រប់គ្រងបន្តិចបន្តួចប៉ុ-

ណ្តឹង តើមានទៅទាស់ខុសអ្វី បានជាលោកចាំបាច់ឈឺឆ្អាលខ្លាំងដែម្ល៉េះ ?...

សំដីនេះធ្វើឲ្យលោកចៅហ្វាយគុយ ពុំអាចទប់កំហឹងដែលកំពុងឆេះពុះកញ្ជ្រោលពេញដើមទ្រូងនោះ តទៅទៀបានឡើយ ។ លោកក្រោកឈរឡើងពើងទ្រូងនិយាយតបវិញ យ៉ាងអង់អាចក្លាហាន ៖

– លោកមេទ័ព ! សូមលោកជ្រាបឲ្យច្បាស់ថា បើលោកមិនព្រមប្រគល់សិទ្ធិសេរីភាព ទៅឲ្យប្រជារាស្ត្រខ្ញុំរស់តាមទម្លាប់ធម្មតាទេនោះ ខ្ញុំត្រូវតែប្តូរស្លាប់ដើម្បីប្រឆាំងតទល់នឹងបញ្ជាផ្តាច់ការរបស់ព្រះចៅមិញម៉ាងជាដាច់ខាត ។

មេទ័ពយួនអុងឡូវឮសំដីសំរេចចិត្តជាចុងក្រោយរបស់លោកចៅហ្វាយគុយ ក៏ផ្ទុះសំណើចចំអកខួរជំរំ ។ មួយសន្ទុះធំ ទើបបើកក្រអូមមាត់បញ្ចេញសំដី ៖

– បើអីចឹងបានសេចក្តីថា លោកធុញទ្រាន់នឹងការរស់នៅហើយឬ ?...

– ពិតប្រាកដណាស់ ! ប៉ុន្តែខ្ញុំមិនមែនចង់ស្លាប់ មុនពេលព្រះអាទិត្យរះ ក្នុងទីងងឹតនោះដែរ ។ យ៉ាងណាមិញ ! ខ្ញុំស្លាប់គឺស្លាប់ដើម្បីជាតិខ្ញុំរស់ ។

មេទ័ពយួនអុងឡូវស្តាប់សំដីលោកចៅហ្វាយគុយ ពុំយល់ន័យក៏បញ្ជាក់សួរជាបន្ទាន់ ៖

– លោកចង់និយាយអំពីអ្វី ? សូមមានប្រសាសន៍ឲ្យច្បាស់លាស់មក ព្រោះភាសាបង្កប់ន័យនេះ ខ្ញុំស្តាប់មិនបានទេ ។

ម្តងនេះលោកចៅហ្វាយគុយមានប្រសាសន៍មួយម៉ាត់ៗយ៉ាងច្បាស់លាស់ ៖

– សំដីរបស់ខ្ញុំគ្មានបង្កប់ន័យអាថ៌កំបាំងអ្វីទេ គឺគ្រាន់តែចង់បញ្ជាក់ប្រាប់លោកថា ខ្លួនខ្ញុំមិនមែនចង់ស្លាប់ដោយឱបក្រសោបយកអយុត្តិធម៌ទៅជាមួយផងនោះទេ ។ បើមុននឹងស្លាប់ ត្រូវតែស្លាប់ដើម្បីជាតិខ្ញុំរស់ ទើបអាចបិទភ្នែកជិតទៅបាន ម៉េចលោកយល់ហើយឬនៅ ?

មេចោរយួនអុងឡូវ ហាក់យល់ន័យបន្តិច ក៏បញ្ជាក់សួរមួយប្រយោគទៀត ៖

–អូ !... លោកចង់ចោទថា ព្រះចៅក្រុងវៀជាជនអមនុស្សធម៌ផងឬ ? ហា៎ស ! ហា៎ស ! ហា៎ស ! ប្រសើរណាស់ ដែលលោកហ៊ានយកជីវិតមកប្តូរនឹងបញ្ជាដាច់ណាត់របស់ព្រះចៅយើងយ៉ាងនេះ ។ តើឥឡូវ លោកនៅត្រូវការអ្វីទៀតឆាប់និយាយឲ្យអស់មក ?...

– សំរាប់រូបខ្ញុំគឺគ្មានចង់បានអ្វី ក្រៅពីសុំឲ្យលោកលុបបំបាត់បញ្ជាដាច់ណាត់របស់ព្រះចៅមិញម៉ាង ដើម្បីទុកទំនៀមទំលាប់ប្រពៃណី និងព្រះពុទ្ធសាសនាខ្មែរឲ្យនៅគង់វង្សដូចដើមវិញនោះឡើយ ។ ម្យ៉ាងទៀត នៅមុនពេលដែលខ្ញុំស្លាប់ ខ្ញុំសុំឲ្យលោកអនុញ្ញាតច្បាប់ឲ្យខ្ញុំពីរយ៉ាងដូចតទៅនេះ ៖

១– សូមលោកចេញប្រកាសជាធរមាន ប្រាប់ទៅបងប្អូនខ្មែរគ្រប់ភូមិស្រុកដែ

លរស់នៅលើដែនដីកម្ពុជាក្រោមនេះ ឲ្យបានជ្រាបគ្រប់ៗគ្នាថា ព្រះរាជបញ្ជាប្រះចៅក្រុងវ៉េ ទុកជាមោឃៈ, បងប្អូនខ្មែរត្រូវតែមានសិទ្ធិសេរីភាព ក្នុងការកាន់ទំនៀមទំលាប់ប្រពៃណី និងគោរពព្រះពុទ្ធសាសនាខ្មែរឡើងវិញទាំងអស់ ។

២- ក្នុងខណៈដែលលោកបណ្ដើរខ្ញុំយកទៅសម្លាប់ ទោះបីកន្លែងណាឬដោយវិធីណាក៏ដោយ សូមលោកអនុញ្ញាតឲ្យខ្ញុំ បានជួបមុខប្រជាជាតិចំនួនកន្លះម៉ោងជាមុនសិន ដើម្បីសំណេះសំណាលគ្នាឲ្យអស់ចិត្ត មុនពេលដែលត្រូវស្លាប់ ។

មេទ័ពយួនអុងឡូវស្ដាប់ឮហើយ ក៏ងក់ក្បាលញាប់ស្មេក បញ្ជាក់នូវការយល់ព្រមដោយមិនបាច់ព្រៀងទុក ៖

– ការសំរេចចិត្តរបស់លោកនេះប្រសើរមែន ! ខ្ញុំជឿជាក់ថាព្រះចៅក្រុងវ៉េមិនជំទាស់នឹងបំណងនេះទេ ។

មួយអាទិត្យក្រោយមក មេទ័ពយួនអុងឡូវបានចេញប្រកាសផ្ញើដំណឹងទៅឲ្យបងប្អូនខ្មែរគ្រប់ភូមិស្រុក និងព្រះសង្ឃទាំង៥០៧វត្ត ឲ្យបានជ្រាបពីការលប់បំបាត់ព្រះរាជបញ្ជារបស់ព្រះចៅមិញម៉ាំងចោលចេញ ដោយទុកសិទ្ធិសេរីភាពឲ្យជនជាតិខ្មែរទាំងអស់រស់នៅដូចធម្មតា ព្រមទាំងបញ្ជាក់យ៉ាងច្បាស់ថា ៖ លោកចៅហ្វាយគុយ ជាអ្នកធ្វើអន្តរាគមន៍ប្ដូរស្លាប់ក្នុងរឿងនេះ !

ដំណឹងនេះបានធ្វើឲ្យព្រះសង្ឃនិងប្រជារាស្ត្រខ្មែរសប្បាយរីករាយក្នុងចិត្តខ្លាំងណាស់ ។ ប៉ុន្តែមិនបានប៉ុន្មានថ្ងៃផង ក៏ត្រូវទទួលទុក្ខសោកវិយោគទៅវិញ ព្រោះលោកចៅហ្វាយគុយ ដែលជាអ្នកមានគុណទាមទារសិទ្ធិសេរីភាពនោះ ត្រូវពួកយួនមួយចំនួនធំចាប់ដាក់ខ្នោះបណ្ដើរ យកទៅកាន់កន្លែងពិឃាតយ៉ាងអណោជអធ៌ម

ក្នុងខណៈនោះ បងប្អូនខ្មែរទាំងអស់បាននាំគ្នារត់មកពីគ្រប់ភូមិស្រុក ដើម្បីរង់ចាំក្បួនបណ្ដើរលោកចៅហ្វាយគុយ ហើយសំពះថ្លែងអំណរគុណចំពោះលោកដែលជាវីរបុរសខ្មែរដ៏គំរូ ក្នុងការធ្វើពលិកម្មដើម្បីប្រជារាស្ត្រ និងប្រទេសជាតិជាទីស្រឡាញ់ ។

បងប្អូនខ្មែរទាំងអស់ គ្រាន់តែក្រឡេកឃើញក្បួនបណ្ដើរលោកចៅហ្វាយគុយមកដល់ភ្លាម នឹកខ្លោចផ្សាក្នុងចិត្តយ៉ាងខ្លាំង ទឹកភ្នែកហូរសស្រាក់មករហាមទាំងមិនដឹងខ្លួន ។ មានអ្នកខ្លះស្ទុះទៅឱបលោកវីរបុរស យំរងៀលបោកខ្លួនដូចសត្វអក ធ្វើឲ្យលោកចៅហ្វាយគុយអត់ទ្រាំនឹងការបង្ហូរទឹកភ្នែកតបវិញពុំបានឡើយ ។

តាមឯកសាររបស់ព្រះតេជព្រះគុណ ព្រះទេពកុសល្ល ញាណឈឺន (គង់នៅវត្តសិរីលង្ការ ភ្នំពេញ ស្រុកកំណើតលោកនៅភូមិពិសី ខេត្តព្រះត្រពាំង) បានប-

ញ្ញាក់យ៉ាងច្បាស់ថា នៅមុនពេលប្រហារជីវិតលោកចៅហ្វាយគុយ ប្រជារាស្ត្រខ្មែរបាននាំគ្នារៀបចំគ្រឿងម្ហូបអាហារដាក់លើតុមួយយ៉ាងវែង ក្រាលសំពត់សពណ៌ប្រាក់ចាំងភ្លឺផ្លេក ហើយអញ្ជើញលោកចៅហ្វាយឲ្យចូលទៅទទួលទាន ព្រមទាំងមានព្រះសង្ឃជាច្រើនរយអង្គដែលនិមន្តមកសូត្រធម៌បញ្ជូនកុសលទៀតផង ។

លោកចៅហ្វាយគុយសំដែងការគួរសមនិងទឹកមុខញញឹមធម្មតា ទៅកាន់ព្រះសង្ឃនិងប្រជារាស្ត្រខ្មែរ ដើម្បីលាស្លាប់ជាចុងក្រោយបំផុត ។

បន្ទាប់ពីបានទទួលទានបាយបន្តិចបន្តួច តាមសេចក្តីអញ្ជើញរបស់បងប្អូនខ្មែរជាទីស្រឡាញ់មក លោកចៅហ្វាយគុយក៏ក្រោកឈរឡើង ថ្លែងវាចាផ្តែផ្តាំបងប្អូនខ្មែរនិងព្រះសង្ឃជាទីគោរព ដែលមានសេចក្តីដូចតទៅនេះ ៖

«ខ្ញុំរីករាយចិត្តខ្លាំងណាស់ ដែលបានជួបមុខបងប្អូនរួមលោហិតទាំងអស់ នៅមុនពេលខ្ញុំផុតជីវិតនេះ ។ ខ្ញុំសូមអភ័យទោស ពីសំណាក់បងប្អូនជាទីស្នេហា និងព្រះសង្ឃទាំងអស់ ដោយខ្ញុំព្រះករុណាខ្ញុំបាទពុំមានសមត្ថភាពគ្រប់គ្រាន់នឹងបំរើជាតិមាតុភូមិ ។ ដូច្នេះ ខ្ញុំត្រូវតែបញ្ចប់ជីវិតជូនជាតិ ដោយពុំស្តាយស្រណោះសោះឡើយ ។

ឥឡូវនេះ ទំនៀមទំលាប់ ព្រះពុទ្ធសាសនា និងប្រពៃណីខ្មែរយើង ត្រូវទាមទារបានមកវិញហើយ ។ ហេតុនេះ សូមបងប្អូនរួមជាតិខ្មែរទាំងអស់ នាំគ្នាថែរក្សាឲ្យបានគង់វង្សរៀងរហូតតទៅ កុំឲ្យមានថ្ងៃផុតរលត់ឡើយ ។

សូមបងប្អូនចាំនិងយល់ឲ្យច្បាស់ថា ពូជខ្មែរយើងជាពូជអ្នកចម្បាំង ធ្លាប់មានកេរ្តិ៍ឈ្មោះល្បីសុះសាយពេញសកលលោក ។ ហេតុនេះយើងត្រូវតែមានស្មារតីរឹងប៉ឹង រួមសាមគ្គីគ្នាជានិច្ច កុំជឿពាក្យចាក់រុកបោកប្រាសបំបែកបំបាក់របស់សត្រូវ ឬលក់ក្បាលបំរើនយោបាយដ៏ខ្មៅងងឹតរបស់វា ដោយគិតតែពីប្រយោជន៍បុណ្យស័ក្តិ មាសប្រាក់ផ្ទាល់ខ្លួននោះឲ្យសោះ ។

នៅទីបញ្ចប់នេះ ខ្ញុំជឿជាក់ថា ខ្ញុំម្នាក់ស្លាប់ទៅ នៅមានបងប្អូនកូនខ្មែរជំនាន់ក្រោយជាច្រើនលាននាក់ទៀត ដែលមានឧត្តមគតិខ្ពង់ខ្ពស់ ហ៊ានប្តូរជីវិត ដើម្បីការពារបូរណភាពទឹកដី សេរីភាព និងព្រះពុទ្ធសាសនាខ្មែរឲ្យគង់វង្សពុំខាន ។

សូមបងប្អូនរស់នៅឲ្យបានសុខសប្បាយគ្រប់ៗគ្នាទាំងអស់ចុះ ខ្ញុំសូមលាស្លាប់ថ្ងៃនេះហើយ !...» ។

ប្រជារាស្ត្រនិងព្រះសង្ឃខ្មែរស្តាប់សេចក្តីផ្តែផ្តាំរបស់លោកចៅហ្វាយគុយចប់ក៏នឹកអាណោចអធ័មអួលណែននៅដើមទ្រូង ហូរទឹកភ្នែកស្រក់សស្រាក់ យំលាន់រងំដូចឃ្មុំក្រែបផ្កា ។ តែទោះបីជាយ៉ាងណា ក៏ទាហានយួនអុងឡុវមិនរវល់អើពើដែរ ។ គ្រាន់តែដល់ពេលវេលាដែលសន្ធ្យាភ្លាម ពួកវាក៏នាំគ្នាទៅស្ទុះចាប់អូសលោ

កចៅហ្វាយគុយ ចេញពីក្នុងចំណោមប្រជារាស្ត្រខ្មែរ បណ្តើរយកទៅចងឆ្កាងភ្ជាប់នឹងបង្គោលសសរមួយ ទាំងកណ្តាលថ្ងៃត្រង់ក្តៅស្មើរឆេះដី ។ រំពេជនោះ មេទ័ពអុងឡូវក៏ហូតដាវខ្វាកចេញពីស្រោម បញ្ចេញមុខសស្វាចមើលទៅគួរឲ្យព្រឺសាច់ ។ ជនកំណាចបញ្ចេញអាកប្បកិរិយាដូចជាស្រេកឃ្លានឈាម វិរបុរសខ្មែរខ្លាំងណាស់ ។ វាយារដាវគ្រវីវឹងៗបីបួនដង ក៏កាត់ផ្តាច់ក្បាលលោកចៅហ្វាយគុយដាច់ចេញពីដងខ្លួន ធ្លាក់ខ្ពោកទៅដី ឈាមហូរក្រហមច្រាល់ដូចចាក់ទឹកពីក្អម ។ រាស្ត្រខ្មែរដែលឈរនៅទីនោះ នាំគ្នាខ្ទប់មុខស្រែកទ្រហោយំទ្រហឹងអឹងអាប់ ព្រោះតែការសោកស្តាយវីរបុរសខ្មែរដ៏ជាទីគោរពនេះ ។

តាមឯកសារបញ្ជាក់ថា កន្លែងដែលយួនសម្លាប់លោកចៅហ្វាយគុយ គឺស្ថិតនៅមុខសាលាឃុំប៊ិនឌឹក ត្រង់មានដើមម្កាស់កាលដាំទន្ទឹមគ្នាពីរដើម ជាប់នឹងផ្លូវជាតិ ចាក់បណ្តោយពីខាងជើងទៅត្បូង (ឥឡូវនេះ នៅកន្លែងនោះ យួនបានធ្វើមន្ទីរឃោសនាការទៅហើយ) ។

បន្ទាប់ពីលោកចៅហ្វាយសឺន-គុយ បានបញ្ចប់បេសកកម្មជូនជាតិមាតុភូមិហើយ ប្រជារាស្ត្រនិងព្រះសង្ឃខ្មែរកម្ពុជាក្រោម បាននាំគ្នាសុំអនុញ្ញាតពីមេទ័ពយួនអុងឡូវ យកសពលោកចៅហ្វាយគុយ ទៅធ្វើបុណ្យយ៉ាងអធឹកអធម អស់រយៈពេល៧យប់៧ថ្ងៃ ទើបសំរេចចិត្តបញ្ចុះសពលោកក្នុងចេតិយវត្តពោធិសាលរាជ (នៅមុខព្រះវិហារ) ជារៀងរហូតដល់សព្វថ្ងៃ ។

មហាពលិកម្មដ៏ថ្លៃថ្លារបស់វីរបុរសសឺន-គុយ អតីតប្រមុខខេត្តព្រះត្រពាំង បានដាស់ស្មារតីកូនខ្មែរគ្រប់កាលសម័យទាំងអស់ ឲ្យដក់ជាប់នូវការឈឺចាប់ខ្លោចផ្សា ដែលសាបព្រោះចេញពីចោរយួន សត្រូវប្រវត្តិសាស្ត្ររបស់ខ្មែរ ដោយគ្មានថ្ងៃនឹងបញ្ចប់បានឡើយ ។

# -៧-

# គុណបំណាច់ភូឈ្មួយគង់

លោកចៅហ្វាយគុយបានទទួលមរណភាព ក្រោមសន្ទុះផ្លែដាវស្រួចឈាមរបស់មេចោរយួនអុងឡូវទៅហើយ ។ អស្ចារ្យណាស់ !... មនុស្សល្អរស់មិនបានយូរទេ !...

ចំណែកភូឈ្មួយគង់ ដែលជាជនក្បត់ លក់ក្បាលបំរើសត្រូវស្នូរពូជរបស់ប្រទេសជាតិនោះ តើត្រូវបានទទួលរង្វាន់កិរិតណា ពីមេទ័ពយួនអុងឡូវដែរ ?...

យើងសាកល្បងតាមដានបន្តិចទៀតមើល...

ក្រោយពីបានសំរេចជោគជ័យគ្រប់បែបយ៉ាងហើយ មេទ័ពយួនអុងឡូវក៏រៀបចំពិធីជប់លៀងមួយយ៉ាងគគ្រឹកគគ្រេង ដើម្បីតែងតាំងបុណ្យស័ក្តិជូនលោកភូឈ្មួយគង់ ឲ្យសមនឹងគុណបំណាច់ ដែលគាត់បានក្បត់ជាតិខ្មែរស្រឡាញ់ជាតិយួន ។

ពេលនោះភូឈ្មួយគង់សប្បាយចិត្តណាស់ ញញឹមស្ញេញស្ញាញដូចស្វា បិទមាត់មិនជិតទេ ព្រោះគាត់សង្ឃឹមថា ផលថ្មីប្រាកដជាមានដល់គាត់នៅពេលខាងមុខនេះមិនខាន ។

ពិធីជប់លៀងបានប្រព្រឹត្តទៅយ៉ាងគគ្រឹកគគ្រេង អស់រយៈពេលមួយយប់មួយថ្ងៃ ទើបមេទ័ពយួនអុងឡូវក្រោកឈរឡើងក្រពាត់ដៃនិយាយទៅកាន់ភូឈ្មួយគង់ថា ៖

- សគុណរបស់លោកចំពោះជនជាតិខ្ញុំ មានទំហំធំធេងណាស់ ។ មួយជីវិតនេះ ខ្ញុំប្រាកដជាពុំអាចបំភ្លេចបានទេ !

ភូឈ្មួយគង់ស្តាប់ឮសំដីនេះ ក៏ស្ទុះភ្លែតទៅលត់ជង្គង់សំពះនាយចៅហ្វាយថ្មីតានចរិតវង្វេងជាតិរបស់ខ្លួន ។

មេទ័ពយួនអុងឡូវដកដាវខ្វាកពីស្រោម គ្រវីគ្រវាត់ចុះឡើងគួរឲ្យស្រៀវសាច់ព្រមទាំងស្រែកឡើងក្តែងៗថា ៖

- អញសងគុណឯងនឹងផ្លែដាវនេះ !... ដល់ឯងស្លាប់ទៅ ចាំអញធ្វើបុណ្យឲ្យបានអឹកអធឹកអស្ចារ្យ !...

ភូឈ្មួយគង់ឃើញអាកប្បកិរិយាមេទ័ពយួន ប្រែប្រួលឆាប់រហ័សយ៉ាងនេះ ព្រលឹងនៅចុងសក់ លុតជង្គង់ចុះឲ្យនក្បាលសំពះផ្តោមៗ មាត់ភាវនាធម៌សុំរស់

ញាក់សាច់ញ័រខ្លួនទទ្រើក ។

ប៉ុន្តែរំពេចនោះ ផ្លែដាវដែលធ្លាប់តែប្រទ្បាក់ឈាមរបស់មេទ័ពយួនអុងឡូវ វាត់ខ្វាប់ដាច់ក្បាលភ្លូឈ្មួយគង់ ធ្លាក់ខ្លោកឈាមហូរត្របាញ់ ស្រោចលើធរណីក្រហមច្រាល ។

ពលទាហានយួនទាំងអស់ឃើញដូច្នោះ នាំគ្នាទះដៃស្រែកហ៊ោកងរំពង ដោយសប្បាយចិត្ត ចំពោះការវិនិច្ឆ័យទោសយ៉ាងត្រឹមត្រូវរបស់ចៅហ្វាយនាយ ។

សកម្មភាពទាំងនេះ បានបញ្ជាំងឲ្យឃើញយ៉ាងច្បាស់ នូវគំនិតច្រាសជើងរបស់ចោរយួន ដែលបានចូលមកជាន់ឈ្លី ព្រះសង្ឃនិងនិងប្រជារាស្ត្រខ្មែរស្លូតត្រង់កម្ពុជាក្រោម យ៉ាងឃោរឃៅព្រៃផ្សៃជាទីបំផុត ។

ឥឡូវនេះ ភ្លើងសង្គ្រាមដ៏ចង្រៃនោះ កំពុងតែត្រូវពួកវាបង្កាត់ឲ្យឆេះរាលដាលចូលមកដែនដីកម្ពុជាកណ្តាលយើងទៀតហើយ ។ ដូច្នេះ យើងជាកូនខ្មែរអ្នកស្នេហាជាតិទាំងអស់គ្នា ត្រូវតែក្រោកឈរឡើង វាយកំទេចអំពើព្រៃផ្សៃរបស់យួនគ្រប់ស្រទាប់ ឲ្យវិនាសផុតពូជ ចេញពីទឹកដីខ្មែរទាំងអស់ ដែលកាន់អព្យាក្រឹតនិយមព្រះពុទ្ធសាសនា ។៚

**~ចប់~**

ភ្នំពេញ, ថ្ងៃទី២០ ខែសីហា ១៩៧១

អ្នកនិពន្ធ

**កែវ~សុវត្ថិ**